**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Économiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ទាហានកុមារៈ ឧក្រិដ្ឋកម្មសង្គ្រាម

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ជឹម ស៊ីវហ៊័រ**

**លោក ឆយ វឌ្ឍនា**

ណែនាំដោយ

បណ្ឌិត **អ៊ឹម រដ្ឋា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ទាហានកុមារ៖ ឧក្រិដ្ឋកម្មសង្គ្រាម

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ជឹម ស៊ីវហ៊ីរ**

**លោក ឆយ វឌ្ឍនា**

ណែនាំដោយ

បណ្ឌិត **អ៊ឹង រដ្ឋា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ឆយ ទេវ៉ាន់នា** និងនាងខ្ញុំឈ្មោះ **ខឹង ស៊ីវហ៊ីរ** ជានិស្សិតឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់២៤ ឆ្នាំសិក្សា ២០២៣-២០២៤។

## **យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

**លោកឪពុក** និង **អ្នកម្តាយ** ជាទីគោរព ពុំអាចកាត់ថ្លៃបាន ដែលបានផ្តល់កំណើត និងបីបាច់ចិញ្ចឹមថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងទំនុកបម្រុងដល់យើងខ្ញុំគ្រប់បែបយ៉ាង ទាំងស្មារតី កម្លាំងចិត្ត ថវិកា និងសម្ភារៈដើម្បីឱ្យយើងខ្ញុំបាន សិក្សារៀនសូត្រ រហូតដល់មហាវិទ្យាល័យ មានចំណេះដឹង ជាទ្រព្យធនដែលមិនអាចបាត់បង់ និងជាប្រទីបបំភ្លឺផ្លូវឱ្យខ្ពង់ខ្ពស់នាពេលអនាគត។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំពុះពារស្វែងរកនូវសន្តិភាពពេញលេញ ស្ថេរភាពនយោបាយ ការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍជូនកម្ពុជា អាចឱ្យប្រជាជនខ្មែរគ្រប់រូបបានរស់នៅក្រោមដំបូលសន្តិភាព។

ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងផ្តល់នូវចំណេះដឹង បទពិសោធន៍ជាច្រើន និងខិតខំបណ្តុះបណ្តាលនិស្សិតទាំងអស់ឱ្យក្លាយជាធនធានមនុស្សសម្រាប់សង្គមជាតិ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកបណ្ឌិត **អ៊ុំ រដ្ឋា** ជាសាស្ត្រាចារ្យដឹកនាំ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងកម្លាំងកាយចិត្ត បទពិសោធន៍ ចំណេះដឹងដោយមិនខ្លាចនឿយហត់ ដោយបានដឹកនាំជំរុញក្នុងការសរសេរតាក់តែងសារណាមួយនេះ តាំងពីចាប់ផ្តើមរហូតដល់ការបញ្ចប់ប្រកបដោយជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំទាំងពីររូប សូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ និងបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកយើងនេះ មេត្តាតាមថែរក្សាដល់អ្នកមានគុណ ឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យជួបប្រទះនូវសេចក្តីសុខចម្រើន សុខភាពបរិបូរណ៍ ជន្មាយុយឺនយូរ មានកម្លាំងពលំ និងសម្រេចគ្រប់ភារកិច្ច ជាពិសេសសូមជូនពរឱ្យលោកជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្រោយពីបានសិក្សាអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ ចាប់ពីឆ្នាំ២០២០ រហូតដល់ឆ្នាំ២០២៤ យើងខ្ញុំទទួលបានចំណេះដឹងទាំងផ្នែកច្បាប់ជាតិ និងអន្តរជាតិ រួមទាំងវិធីសាស្ត្រនៃការស្រាវជ្រាវ បើទោះបីជាមានវិបត្តិនៃជំងឺរាតត្បាតកូវីដ១៩ទូទាំងប្រទេសក៏ដោយ។ ទន្ទឹមនឹងវិបត្តិនៃជំងឺកូវីដ យើងឃើញមានបញ្ហាមួយទៀត គឺជម្លោះប្រដាប់អាវុធរវាងក្រុមឧទ្ទាមនៅតាមបណ្តាប្រទេសនានា ពិសេសនៅតំបន់អាហ្វ្រិក។ ភាពខ្វះខាតនៃកងកម្លាំងក្នុងជម្លោះប្រដាប់អាវុធ ជាមូលហេតុដ៏ធំធ្វើឱ្យក្រុមឧទ្ទាមបានកេណ្ឌ និងចាប់បង្ខំកុមារដែលខ្លះចាប់ពីអាយុ ៧ឆ្នាំ រហូតដល់យុវជនអាយុ ១៧ឆ្នាំធ្វើជាទាហាន។

ហេតុដូច្នេះ យើងខ្ញុំទាំងពីរនាក់បានសម្រេចជ្រើសរើសយកនូវប្រធានបទ *ទាហានកុមារៈ ឧក្រិដ្ឋកម្មសង្គ្រាម* នេះមកស្រាវជ្រាវនិងសរសេរចងក្រងជាសារណាបញ្ចប់ការសិក្សា។ សារណានេះមានគោលបំណងឱ្យមិត្តនិស្សិតក៏ដូចជាអ្នកសិក្សាទូទៅទាំងអស់បានស្វែងយល់ អំពីនិយមន័យនៃទាហានកុមារ ធាតុផ្សំឧក្រិដ្ឋកម្មសង្គ្រាម ដែលបានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ១៩៩៨ និងការប្រើប្រាស់ទាហានកុមារនៅតាមបណ្តាប្រទេស ជាមួយនឹងការយល់ដឹងបន្ថែមនូវចំណុចខ្វះខាតដែលធ្វើឱ្យបញ្ហាទាហានកុមារនៅតែកើតមានឡើង។

តាមរយៈស្នាដៃចងក្រងសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សានេះនឹងចូលរួមជាផ្នែកមួយនៃចំណេះដឹងថ្មី និងជាជំនួយដល់ស្មារតីរបស់សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវដែលមានគោលបំណងចង់ស្វែងយល់ និងស្រាវជ្រាវទាក់ទងនឹងទាហានកុមារ (Child Solider) ក្របខណ្ឌគតិយុត្តអន្តរជាតិដែលហាមឃាត់ការប្រើប្រាស់ទាហានកុមារ ព្រមទាំងការកើតឡើងនៃទាហានកុមារពីអតីតកាលជាហេតុធ្វើឱ្យការហាមប្រាមក្នុងការកេណ្ឌ និងប្រើប្រាស់នូវទាហានកុមារ មួយវិញទៀតវិធាននេះបានក្លាយជាផ្នែកមួយនៃទំនៀមទម្លាប់អន្តរជាតិដែលគ្រប់បណ្តាលរដ្ឋទាំងអស់ត្រូវតែគោរព និងប្រតិបត្តិតាម។

យ៉ាងណាមិញ ដោយសារតែពេលវេលាក្នុងការសិក្សាស្រាវជ្រាវ និងការចងក្រងសារណាបញ្ចប់ការសិក្សាមានរយៈពេលខ្លី ជាការពិតណាស់តែងតែកំហុសដែលអាចកើតឡើងដោយអចេតនាមួយចំនួន និងចំណុចខ្វះខាតមិនទាន់គ្រប់ជ្រុងជ្រោយនៅត្រង់ចំណុចណាមួយជាក់ជាមិនខាន។ ទន្ទឹមនឹងគ្នានេះដែរ យើងខ្ញុំសូមអភ័យទោសទុកជាមុន ព្រមទាំងរីករាយនិងទទួលការរិះគន់ ដើម្បីស្តាបនាពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកសិក្សាស្រាវជ្រាវ មិត្តរួមជំនាន់ ប្អូនៗជំនាន់ក្រោយ និងអ្នកអានទាំងអស់ រាល់កំហុសឆ្គងនូវអក្ខរាវិរុទ្ធ ពាក្យពេចន៍ ផ្នែកខ្លឹមសារ និងវិធីសាស្ត្រក្នុងការសរសេរ។

# មាតិកា


**សេចក្ដីផ្ដើម** ........ ១

១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំនិងដែនកំណត់ ........ ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៦. រចនាសម្ព័ន្ធ ........ ៣


## ជំពូកទី១

## សញ្ញាណទូទៅនៃទាហានកុមារ


១.១. និយមន័យ ........ ៤

១.២. ទ្រឹស្ដីហាមប្រាមមិនឱ្យប្រើប្រាស់ទាហានកុមារ ........ ៥

១.២.១. ច្បាប់មនុស្សធម៌អន្តរជាតិ ........ ៥

១.២.២. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ........ ៧

១.២.៣. នីតិព្រហ្មទណ្ឌអន្តរជាតិ ........ ៨

១.២.៤. អនុសញ្ញាស្ដីពីសិទ្ធិកុមារ ........ ៩

១.២.៥. សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ........ ១០

១.៣. ទំនាក់ទំនងឧក្រិដ្ឋកម្មសង្គ្រាម និងជម្លោះប្រដាប់អាវុធ ........ ១២


## ជំពូកទី២

## ការប្រើប្រាស់ទាហានកុមារនៅក្នុងសង្គ្រាមជាក់ស្ដែង


២.១. ទាហានកុមារអំឡុងពេលសង្គ្រាមលោកលើកទី២ ........ ១៣

២.១.១. ប្រទេសអាឡឺម៉ង់ ........ ១៣

២.១.២. ប្រទេសជប៉ុន ..................................................................... ១៣
២.២.ទាហានកុមារក្រោយសង្គ្រាមលោកលើកទី២ ..................................................... ១៤
២.២.១. ក្នុងសតវត្សទី ២០ ..................................................................... ១៤
២.២.២. ដើមសតវត្សទី ២១ ..................................................................... ១៨
២.៣.ផលវិបាក ..................................................................... ២២
២.៣.១. ផលវិបាកដោយផ្ទាល់ ..................................................................... ២២
២.៣.២. ផលវិបាកដោយប្រយោល ..................................................................... ២៣

## ជំពូកទី៣

## ដំណោះស្រាយបញ្ឈប់ការប្រើប្រាស់ទាហានកុមារ

៣.១.ការកាត់ទោសរបស់តុលាការ ជាទម្រង់នៃការគាំពារទាហានកុមារ ..................................... ២៥
៣.១.១. សាលក្រមរបស់តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន ..................................... ២៥
៣.១.២. សាលក្រមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ..................................... ២៩
៣.២.ចំណុចខ្វះចន្លោះនៃច្បាប់អន្តរជាតិចំពោះការបញ្ឈប់ការប្រើប្រាស់ទាហានកុមារ ..................... ៣៥
សេចក្តីសន្និដ្ឋាន ..................................................................... ៣៩
អនុសាសន៍ ..................................................................... ៤០
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

សង្គ្រាមជាការណ៍ដែលបុគ្គលគ្រប់ៗគ្នាមិនចង់ជួបប្រទះដោយសារតែរាល់សង្គ្រាមរមែង តែងតែផ្ដល់នូវវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិ និងស្លាប់មនុស្សច្រើនជាពិសេសជន ស៊ីវិលស្លូតត្រង់។ សង្គ្រាមក៏បង្កឱ្យមានការប៉ះពាល់ទាំងផ្លូវកាយ និងផ្លូវអារម្មណ៍ដល់ជន ដែលបានរងផលប៉ះពាល់ទាំងអំឡុងពេលសង្គ្រាម និងក្រោយសង្គ្រាមបានបញ្ចប់។ ជាមួយគ្នានេះដែរ កុមារក៏ជាជនរងគ្រោះខ្លាំងផងដែរដោយកុមារបានជួបប្រទះ និងបានឃើញដោយផ្ទាល់ពីភាពសាហាវឃោរឃៅ របស់ទាហានដែលបានប្រព្រឹត្តមកលើខ្លួន និងទៅលើប្រជាជនស្លូតត្រង់ផ្សេងទៀត។ យ៉ាងណាមិញក្នុងការធ្វើសង្គ្រាមរវាងគ្នា និងគ្នាដែលភាគច្រើនជាជម្លោះប្រដាប់អាវុធក្នុងប្រទេស ពោលគឺរវាងរដ្ឋ និងក្រុមឧទ្ទាមប្រដាប់អាវុធ ដែលចង់កាន់កាប់តំបន់ភាគច្រើនដែលគេឃើញកើតមាននៅទ្វីបអាហ្វ្រិកនោះ គឺក្រុមឧទ្ទាមធ្វើសង្គ្រាមជាមួយរដ្ឋដោយមានការយកកុមារដែលរស់នៅក្នុងតំបន់ដែលខ្លួនកាន់ កាប់នោះមកធ្វើជាទាហាន ដើម្បីបម្រើឱ្យក្រុមកងកម្លាំងរបស់ខ្លួន ដោយហេតុថាក្រុមឧទ្ទាម នោះភាគច្រើនមិនមានចំនួនគ្រប់គ្រាន់ និងមិនមានការចេះដឹងលើការហាមឃាត់មិនឱ្យមានការប្រើកុមារ។

រដ្ឋជាច្រើននៅទ្វីបអាហ្វ្រិកគឺធ្វើសង្គ្រាមរវាងរដ្ឋខ្លួនឯងនិងក្រុមឧទ្ទាមដែលភាគច្រើនចង់កាន់កាប់ទឹកដីកាន់កាប់តំបន់ដែលមានរ៉ែ មានការបែងចែកជាតិសាសន៍ និងផ្ទត់គំនិតនយោបាយនៃការគ្រប់គ្រងប្រទេស។ តំបន់រ៉ែមានតម្លៃជាហេតុនាំឱ្យមានការដណ្ដើម កាប់កាប់ដោយសារវាអាចផ្ដល់អត្ថប្រយោជន៍ច្រើនដល់ក្រុមទាំងនោះ ទាំងអាចរកចំណូល និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើសង្គ្រាម តួយ៉ាងនៅប្រទេសសេរ៉ាឡេអូនក្រុមរណសិរ្សរួបរួមបដិវត្តន៍ បានកាន់កាប់គ្រប់គ្រងអណ្ដូងរ៉ែពេជ្រ ដែលបានផ្ដល់កម្រៃ និងអាចមានលទ្ធភាពធ្វើសង្គ្រាមបាន។ យ៉ាងណាមិញកុមារដែលត្រូវបានចាប់យកមកធ្វើជាទាហាននោះភាគច្រើនជាសមាជិកនៃក្រុមប្រជាជនដែលរស់នៅ តំបន់ដែលត្រូវបានកាន់កាប់នោះ ហើយពួកគេត្រូវបានគេ ចាប់បង្ខំឱ្យប្រើសារធាតុញៀនដែលអាចបង្វក់កុមារឱ្យធ្វើតាមបញ្ជារបស់ខ្លួន និងមិនអាចគ្រប់គ្រងខ្លួនឯងបាន រួមទាំងឈានដល់ការសម្លាប់អ្នកដទៃក្រោមការបញ្ជារបស់មេឧទ្ទាមផងដែរ។ ដោយមើលឃើញបែបនេះហើយ សហគមន៍អន្តរជាតិបានបន្ថែមការយកចិត្តទុក ដាក់លើការចាប់យកកុមារមកធ្វើជាទាហាន តួយ៉ាងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបង្កើតមកដើម្បីកាត់ទោសបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតក្រោមដែន យុត្តាធិការរបស់ខ្លួនរួមទាំងការចាប់យក និងបញ្ចូលកុមារឱ្យចូលក្នុងក្រុមប្រដាប់អាវុធ។

ដូចនេះប្រធាននៃការស្រាវជ្រាវនេះនឹងសិក្សាទៅលើ *ទាហានកុមារៈ ឧក្រិដ្ឋកម្មសង្គ្រាម*។

## ២. ចំណោទបញ្ហា

ទាហានកុមារនៅតែជាប្រធានបទដែលមានការយកចិត្តទុកដាក់ពីសហគមន៍អន្តរជាតិ និងមានការប៉ះពាល់ដល់ជីវិតនិងការរៀនសូត្ររបស់កុមារជាច្រើន យ៉ាងណាមិញការកេណ្ឌ និងចាប់យកកុមារមកធ្វើជាទាហានភាគច្រើនមាននៅក្នុងបណ្តាលប្រទេសក្នុងទ្វីបអាហ្វ្រិក ដូចនេះហើយបានជាមានចំណោទបីលើកឡើងថា៖

១. តើមានមានលិខិតបទដ្ឋានគតិយុត្តអ្វីខ្លះ បានការពារកុមារពីការយកមកធ្វើជាទាហាន?
២. ក្រោយពីបានធ្វើជាទាហានកុមារ តើកុមារទាំងនោះរងនូវផលប៉ះពាល់អ្វីខ្លះ?
៣. តើមានដំណោះស្រាយ និងចំណុចខ្វះខាតអ្វីខ្លះដើម្បីបញ្ឈប់ទាហានកុមារ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាមួយនេះ គឺដើម្បីចែករំលែកពុទ្ធិដល់ និស្សិត អ្នកសិក្សាស្រាវជ្រាវឱ្យយល់ដឹងអំពី៖

- និយមន័យ នៃទាហានកុមារ
- មូលហេតុនៃការយកកុមារមកធ្វើជាទាហានក្នុងពេលសង្គ្រាម
- លិខិតបទដ្ឋានអន្តរជាតិដែលមានគោលបំណងការពារកុមារពីការយកចូលធ្វើទាហាន
- ការប្រើប្រាស់ទាហានកុមារក្នុងសង្គ្រាមជាក់ស្តែង
- ផលវិបាកទាំងផ្លូវកាយរបស់កុមារដែលធ្លាប់ត្រូវបានគេកេណ្ឌមកធ្វើជាទាហាន និង វិបត្តិខាងស្មារតី
- យល់ដឹងអំពីការសម្រេចសេចក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអំពីការយកកុមារមកធ្វើជាទាហាន
- ចំណុចខ្វះខាតនៃច្បាប់អន្តរជាតិក្នុងការបញ្ឈប់ការប្រើប្រាស់ទាហានកុមារ

## ៤. ទំហំនិងដែនកំណត់

សារណាស្រាវជ្រាវនេះមានវិសាលភាពនៃការស្រាវជ្រាវ ចាប់ពីក្រោយសង្គ្រាមលោកលើកទី២ និងមកដល់ដើមសតវត្សទី២១នេះប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ ដោយសារតែមានព្រឹត្តិការណ៍ជាច្រើនកើតឡើងជុំវិញពិភពលោកនេះ ដោយខ្លះត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងខ្លះទៀតមិនត្រូវបានផ្សព្វផ្សាយនោះទេ ដូច្នេះយើងខ្ញុំនឹងមិនអាចមានព័ត៌មាន និងពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមានសង្គតភាពលើគ្រប់ទិដ្ឋភាព និងគ្រប់មជ្ឈដ្ឋាននោះទេ។ ទន្ទឹមនឹងការស្រាវជ្រាវនេះដែរ គឺផ្តោតទៅលើឯកសារ និងព័ត៌មានដែលមានស្រាប់ ដោយ

យើងខ្ញុំមិនបានទៅធ្វើការសម្ភាស ឬចុះទៅផ្ទាល់ ឬសង្កេតការណ៍លើដំណើរការនីតិវិធីរបស់តុលាការនោះទេ។ បន្ថែមពីលើនេះទៀតនៅក្នុងជំពូកដែលទាក់ទិននិងការប្រើប្រាស់ទាហានកុមារនោះគឺយើងខ្ញុំចាប់ផ្ដើមពីដំណាក់កាលសង្គ្រាមលោកលើកទី២ និងមកដល់ឆ្នាំ២០២៣ តែប៉ុណ្ណោះដោយហេតុថាប្រទេសដែលយើងខ្ញុំនឹងលើកមកនេះ គឺទទួលបានការចាប់អារម្មណ៍ពីសហគមន៍អន្តរជាតិ និងប៉ះពាល់ដល់សន្តិសុខពិភពលោក។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវប្រធានបទសារណានេះ យើងខ្ញុំពឹងផ្អែកចម្បងទៅលើលិខិតបទដ្ឋានគតិយុត្តអន្តរជាតិសំខាន់ៗដែលបានអនុម័តដោយអង្គការសហប្រជាជាតិ សេចក្ដីសម្រេចរបស់តុលាការអន្តរជាតិ ដូចជាតុលាការនូរ៉ឹមប៊ែក តុលាការឧក្រិដ្ឋកម្មសម្រាប់អតីតយូហ្គោស្លាវី តុលាការពិសេសសម្រាប់សេរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ បន្ថែមលើនេះទៀត យើងខ្ញុំក៏បានដកស្រង់ចេញពី ជើនណាល (Journal) របស់គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម និង ជេស្ទរ (Jstor) រួមទាំងសៀវភៅផ្សេងៗទៀតលើអ៊ីនធើណែតដើម្បីយោង និងគាំទ្រដល់ការស្រាវជ្រាវមួយនេះ។

## ៦. រចនាសម្ព័ន្ធ

សារណានៃការស្រាវជ្រាវនេះ បានបែងចែកដូចខាងក្រោមជា ៣ជំពូក៖

- ជំពូកទី១៖ សញ្ញាណទូទៅនៃទាហានកុមារ ដែលយើងខ្ញុំនឹងបង្ហាញអំពីនិយមន័យនៃទាហានកុមារលិខិតបទដ្ឋានគតិយុត្តិដែលបានហាមប្រាមមិនឱ្យមានការយកកុមារមកធ្វើជាទាហាន និងប្រវត្តិរបស់លិខិតបទដ្ឋានគតិយុត្តិទាំងអស់នោះតែមានលក្ខណៈសង្ខេប។
- ជំពូកទី២៖ ការប្រើប្រាស់ទាហានកុមារ នៅក្នុងសង្គ្រាមជាក់ស្ដែងដែលក្នុងជំពូកនេះយើងខ្ញុំនឹងលើកបង្ហាញនូវការយកកុមារមកធ្វើជាសង្គ្រាមតាំងពីសង្គ្រាមលោកលើកទី២ រហូតដល់ សតវត្សចុងក្រោយនេះ ដោយបង្ហាញពីមូលហេតុខ្លះដែលនាំឱ្យមានការយកកុមារ មកធ្វើជាទាហាន និងសេចក្ដីសម្រេចរបស់តុលាការ រួមទាំងផលប៉ះពាល់ដល់កុមារ។
- ជំពូកទី៣៖ ដំណោះស្រាយបញ្ឈប់ការប្រើប្រាស់ទាហានកុមារ តាមប្រព័ន្ធតុលាការអន្តរជាតិ និងតុលាការ Ad Hoc ដោយកាត់ទោសមេដឹកនាំ ប្រព្រឹត្តទង្វើទាំងនេះរួមនឹងចំណុចខ្វះខាតនៃច្បាប់ដែលពិបាកក្នុងការកាត់ទោសលើជនដែលប្រព្រឹត្តបទឧក្រិដ្ឋកម្មមួយនេះ។

# ជំពូកទី១
# សញ្ញាណទូទៅនៃអាហារ
# កុមារ

# ជំពូកទី១: សញ្ញាណទូទៅនៃទាហានកុមារ

## ១.១. និយមន័យ

ជាទូទៅ កុមារត្រូវបានគេឱ្យនិយមន័យជាច្រើនបែបតែតាមដើម្បីឱ្យស្របតាមការសិក្សាស្រាវជ្រាវតាមទំហំនៃអត្ថបទនេះ ពាក្យកុមារនឹងត្រូវបានយក ស្របតាមបទដ្ឋានគតិយុត្ត អន្តរជាតិជាធរមានមកធ្វើជាការសំអាងប៉ុណ្ណោះ។ ជាក់ស្តែងស្របតាមមាត្រា១នៃអនុសញ្ញាស្តីពីសិទ្ធិកុមារបានឱ្យនិយមន័យទូលាយថា បុគ្គលដែលមានអាយុតិចជាង ១៨ឆ្នាំ ត្រូវបានចាត់ទុកថាជាកុមារ។[១]

ទាហានត្រូវបានផ្តល់និយមន័យថាជាបុគ្គលទាំងឡាយណាដែលបានចូលរួមដោយផ្ទាល់នៅ ក្នុងអរិភាពឬជម្លោះប្រដាប់អាវុធរវាងរដ្ឋនិងរដ្ឋ[២] ក្នុងជម្លោះប្រដាប់អាវុធដែលមានទម្រង់ជាអន្តរជាតិ[៣] និងរវាងរដ្ឋនិងក្រុមឧទ្ទាមនៅក្នុងប្រទេសមួយដែលក្នុងទម្រង់ជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈជាអន្តរជាតិ។[៤]

ជាមួយគ្នានេះដែរ ក៏មានក្រុមទាហានមួយទៀតគឺ ក្រុមទាហានស៊ីឈ្នួលដែលភាគច្រើនត្រូវបានគេស្គាល់ថាជាក្រុមទាហាន ដែលត្រូវបានជួល ដើម្បីឱ្យប្រយុទ្ធនៅប្រទេសទីបីដែលមិនមែនជាប្រទេសកំណើតរបស់ខ្លួននិងប្រតិបត្តិការប្រយុទ្ធ ដើម្បីតែលុយ ឬរង្វាន់ផ្សេង[៥] ហើយនឹងមិនទទួលបានសិទ្ធិការពារជាឈ្លើយសឹកនៃសង្គ្រាមតាមរយៈអនុសញ្ញាទីក្រុងហ្សឺណែវទី៣ ឆ្នាំ១៩៤៩ ស្តីពីការការពារឈ្លើយសឹកនោះទេ ប្រសិនបើត្រូវគេចាប់បានក្នុងពេលប្រតិបត្តិការរបស់ខ្លួន។[៦] ទាហានកុមារគឺជាការរំឮកអំពីទុក្ខលំបាក និងការដែលមិនអនុវត្តច្បាប់មនុស្សធម៌ដែលបង្កឡើងដោយសង្គ្រាមស៊ីវិល។[៧]

ទាហានកុមារ គឺជាបុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ និងបានចូលរួមជាផ្នែកមួយនៃកងកម្លាំងប្រដាប់អាវុធដែលជាភាគីជម្លោះនៅក្នុងសង្គ្រាម រួមបញ្ចូលទាំងការងារផ្សេងៗទៀត ដូចជា ការងារផ្ទះបាយបម្រើឱ្យមេ

---

[១] អនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ ១៩៨៩, មាត្រា១។

[២] ពិធីសារបន្ថែមទី១ នៃអនុសញ្ញាក្រុងហ្សឺណែវ ១៩៧៧, មាត្រា ៤៣(២)។

[៣] អនុសញ្ញាក្រុងហ្សឺណែវ ១៩៤៩, មាត្រា ២ រួម (*common article 2*)។

[៤] អនុសញ្ញាក្រុងហ្សឺណែវ ១៩៤៩, មាត្រា ៣ រួម (*common article 3*)។

[៥] *សូមមើល* វាក្យស័ព្ទរបស់គណៈកម្មធិការកាកបាទក្រហមអន្តរជាតិ *រកបានលើគេហទំព័រ* https://casebook.icrc.org/a_to_z/glossary/private-military-and-security-companies-pmscs

[៦] ពិធីសារបន្ថែមទី១ នៃអនុសញ្ញាក្រុងហ្សឺណែវ ១៩៧៧, មាត្រា ៤៧។

[៧] *សូមមើល* Lasley, Trace, and Clayton Thyne, *Secession, Legitimacy and the Use of Child Soldiers*, *Conflict Management and Peace Science* 32, no. 3 (2015): 289–308. https://www.jstor.org/stable/26271390.

របស់ខ្លួន អ្នកនាំសារ ចារកិច្ច និងការងារផ្សេងៗទៀតអំឡុងពេលសង្គ្រាម។[៨] ដូចគ្នានេះដែរ ឧក្រិដ្ឋកម្មសង្គ្រាមជាឧក្រិដ្ឋកម្មអន្តរជាតិមួយ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[៩] និងបានកំណត់ន័យថាជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើ អនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចអនុវត្តពេលមានជម្លោះប្រដាប់អាវុធ ទាំងទម្រង់ដែលមានលក្ខណៈអន្តរជាតិ និងមិនមែនអន្តរជាតិ។[១០]

## ១.២. ទ្រឹស្តីហាមប្រាមមិនឱ្យប្រើប្រាស់ទាហានកុមារ

### ១.២.១.ច្បាប់មនុស្សធម៌អន្តរជាតិ

នៅឆ្នាំ១៨៥៩ លោក Henry Dunant ដែលជាពាណិជ្ជករជនជាតិស្វីសបានធ្វើដំណើរទៅកាន់ប្រទេសអ៊ីតាលីអំឡុងពេលធ្វើដំណើរគាត់បានឃើញសង្គ្រាមរវាងបារាំង-អូទ្រីស ដែលបានបង្ករបួស និងស្លាប់ជាច្រើន។ សង្គ្រាមនេះត្រូវបានសម្គាល់ដោយការស្លាប់បាត់បង់ជីវិតយ៉ាងធ្ងន់ធ្ងរដោយជនជាតិអូទ្រីសបានបាត់បង់ទាហានប្រហែល ៤០,០០០ នាក់ ហើយកងកម្លាំង Franco-Piedmontese បានបាត់បង់ទាហានប្រហែល ២៨,០០០ នាក់។ ដោយបានឃើញពីលទ្ធផលនៃសមរភូមិ Solferino ក្នុងអំឡុងសង្គ្រាមបារាំង និងអូទ្រីសនិងដោយមានកង្វះខាតខាងវេជ្ជសាស្ត្រ និងមានទាហានដួលស្លាប់របួសជាច្រើនបានបន្សល់ទុកនៅសមរភូមិគាត់ក៏បានយកបទពិសោធន៍ ដែលបានជួបប្រទះនេះសរសេរសៀវភៅមួយក្បាលដែលមាន ចំណងជើងថា "A Memory of Solferino" ដែលបានអំពាវនាវឱ្យបង្កើតសមាគមសង្គ្រោះដោយស្ម័គ្រចិត្តដើម្បីជួយនិងថែទាំអ្នករបួសក្នុងអំឡុងពេលសង្គ្រាម និងដោយបានបង្កើតកាកបាទក្រហមអន្តរជាតិដែលនាំទៅដល់ការអភិវឌ្ឍន៍ច្បាប់មនុស្សធម៌អន្តរជាតិ (International Humanitarian Law) និងអនុសញ្ញាទីក្រុងហ្សឺណែវដើម្បីការពារអ្នករបួសនិងបង្កើតច្បាប់សម្រាប់ការព្យាបាលមនុស្សធម៌ក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ។

នីតិមនុស្សធម៌អន្តរជាតិមានប្រវត្តិយូរមកហើយ ចាប់តាំងសង្គ្រាមស៊ីវិលនៅសហរដ្ឋអាមេរិច អំឡុងឆ្នាំ ១៨៦១ ដល់ ១៨៦៥ ដែលក្នុងពេលនោះ លោក Francis Lieber ដែលជាអ្នកច្បាប់ជនជាតិអាឡឺម៉ង់ អាមេរិកបានសរសេរនៅឆ្នាំ១៨៦៣ ដោយហើយត្រូវបានអនុម័តដោយកងទ័ពក្នុងអំឡុងសង្គ្រាមស៊ីវិលនៅអាមេរិក។

---

[៨] *សូមមើល* David J Francis, *Paper Protection Mechanisms: Child Soldiers and the International Protection of Children in Africa's Conflict Zones*, (2007), The Journal of Modern Africa Studies 207, p.210; ពិធីសារបន្ថែមទី១ នៃអនុសញ្ញាក្រុងហ្សឺណែវ ១៩៧៧, មាត្រា ៤៧ និង៤៧; កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ២៤។

[៩] លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ១៩៩៨, មាត្រា ៥។

[១០] លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ១៩៩៨, មាត្រា ៨។

អនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ត្រូវបានអនុម័តដោយអនុម័តនៅថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ ដោយសន្និសីទការទូតស្តីពីការបង្កើតអនុសញ្ញាអន្តរជាតិ សម្រាប់ការការពារជនរងគ្រោះក្នុងពេលសង្គ្រាម ដែលបានធ្វើឡើងនៅក្នុងទីក្រុងហ្សឺណែវប្រទេសស្វីស។ អនុសញ្ញានេះត្រូវបានគេស្គាល់ម្យ៉ាងទៀតថា ជាច្បាប់ក្នុងពេលសង្គ្រាមដែលជាផ្នែកមួយនៃនីតិអន្តរជាតិដែលមានគោលបំណង គ្រប់គ្រងជម្លោះប្រដាប់អាវុធនិងការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម រួមទាំងកម្រិតអំពីការប្រើប្រាស់អាវុធ និងវិធីសាស្ត្រនៃការធ្វើសង្គ្រាម (means and method of warfare)។[១១] ជាមួយគ្នានេះដែរច្បាប់មនុស្សធម៌ក៏បានកំណត់ អំពីការចាប់យកកុមារមកធ្វើជាទាហានផងដែរ។ ជាទូទៅ កេណ្ឌ ឬការចាប់យកកុមារដែលមិនទាន់គ្រប់អាយុមកធ្វើជាទាហានត្រូវបានគេកំណត់ថាជាឧក្រិដ្ឋកម្មសង្គ្រាមដែលខុសនឹងច្បាប់អន្តរជាតិ។ ពិតណាស់នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិបានកម្រិត និងកំណត់ពីអាយុ កុមារដែលមានអាយុតិចជាង១៥ឆ្នាំ នឹងមិនត្រូវបានចាប់មកធ្វើជាទាហាននិងក្រុមនៃជម្លោះប្រដាប់អាវុធឡើយ។ អនុសញ្ញាទីក្រុងហ្សឺណែវទី៤ បានកំណត់ពីការកម្រិតនេះ៖

> An Occupying Power must not enlist children on the occupied territory [...] below the age of 15 years. [១២]

សូមកត់សម្គាល់ផងដែរថាពាក្យ កាន់កាប់គ្រប់គ្រង (Occupy) គឺទឹកដីរបស់រដ្ឋមួយ នោះគឺស្ថិតក្រោមការគ្រប់គ្រងរបស់កងកម្លាំងរបស់សមាជិកនៃក្រុមប្រដាប់អាវុធមួយក្រុម ទៀតដែលជាគូបដិបក្ស។[១៣] ជាទឡ្ហីករណ៍ បច្ចុប្បន្ននេះ ទឹកដីបាលេស្ទីនគឺត្រូវបានគ្រប់គ្រង (Occupy) ដោយអ៊ីស្រាអែល។[១៤]

ដូចនេះរាល់កុមារដែលមានអាយុក្រោម ១៥ឆ្នាំនឹងត្រូវបានការពារជាដាច់ខាត ក្នុងករណីដែល ប្រទេសរបស់ខ្លួនត្រូវបានគេគ្រប់គ្រង និងកាន់កាប់ក៏ដោយ ក៏កងកម្លាំងដែលបានកាន់កាប់ទឹកដីនោះ មិនមានសិទ្ធិចាប់យកកុមារដែលរស់នៅតំបន់ដែលកាន់កាប់នោះមកធ្វើជាទាហានកុមារបម្រើឱ្យខ្លួនបានទេ។

---

[១១] ពិធីសារបន្ថែមទី១ នៃអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៧៧, មាត្រា ៣៥។

[១២] អនុសញ្ញាក្រុងហ្សឺណែវទី៤ ឆ្នាំ១៩៤៩, មាត្រា ៥០។

[១៣] បទប្បញ្ញត្តិទីក្រុងឡាអេ ឆ្នាំ១៩០៧, មាត្រា៤២។

[១៤] *សូមមើល* តុលាការយុត្តិធម៌អន្តរជាតិ *Legal Consequences Arising From The Policies And Practices of Israel In The Occupied Palestinian Territory, Including East Jerusalem*, *យោបល់ពិគ្រោះ [advisory opinion]*, ចុះថ្ងៃទី ១៩ កក្កដា ឆ្នាំ ២០២៤, *រកបានលើគេហទំព័រ* https://www.icj-cij.org/sites/default/files/case-related/186/186-20240719-adv-01-00-en.pdf

### ១.២.២. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

នីតិសិទ្ធិមនុស្សជាវិធាននៃនីតិអន្តរជាតិដែលបានចែងពីសិទ្ធិសេរីភាពរបស់មនុស្សគ្រប់រូប។ ទន្ទឹមនឹងគ្នានេះដែរការវិវត្តិរបស់ច្បាប់សិទ្ធិមនុស្សបានចាប់ផ្តើមពីសម័យកាលសង្គ្រាមរវាងសហរដ្ឋអាមេរិចដែលទាមទារឯករាជ្យពីចក្រភពអង់គ្លេស រហូតដល់បានការបង្កើតអនុសញ្ញារដ្ឋ Virginia ឆ្នាំ ១៧៧៦ ដោយ Thomas Jefferson ដែលបានយកគំរូពី Bill of Rights from the United Kingdom ដែលបានចែងអំពីសិទ្ធិសំខាន់ៗដូចជាសិទ្ធិរស់រានមានជីវិត និងសេរីភាព។ ដូចគ្នានេះដែរ នៅប្រទេសបារាំងកាលសតវត្សទី ១៨ គឺមាន ការបែងចែកវណ្ណៈសង្គមជាបីគឺ បព្វជិត (*the Clergy*), អភិជន (*the Nobility*), និងមនុស្សសាមញ្ញ (*the Commoner*) ។ កាលនោះ បព្វជិត (*the Clergy*), អភិជន (*the Nobility*) មិនបានខ្វាយខ្វល់ អំពីសេដ្ឋកិច្ចជាតិ និងរស់នៅដោយសុខស្រួល ដែលផ្ទុយនិងឋានៈជាន់ទាបរស់នៅក្នុងភាពក្រីក្រ និងខ្វះអាហារហូបចុក។ មិនតែប៉ុណ្ណោះ មនុស្សសាមញ្ញ (*the Commoner*) ត្រូវជាប់ពន្ធគ្រប់បែបយ៉ាង និង បានធ្វើការដោយបង្ខំដោយមិនបានប្រាក់ជាដើម ខណៈពេលដែលឋានៈជាន់ខ្ពស់រស់នៅដោយសុខ ស្រួល និងបានគិតពន្ធតិច។

រហូតដល់ថ្ងៃទី ១៤ កក្កដា ១៧៨៩ គឺមានមហាបដិវត្តបារាំងដែលប្រជាជន មកពីគ្រប់ខេត្តបាននាំគ្នាវាយដណ្តើមយកបន្ទាយ និងពន្ធនាគារ Bastille ដែលប្រជាជនជឿថាមាន គ្រាប់រំសេវដែលបានរក្សាទុកនៅក្នុងនោះ រួមទាំងរំដោះអ្នកទោសនយោបាយទាំង ៧។

ក្រោយមកនៅថ្ងៃទី ២៦ សីហា ១៧៨៩ មានការអនុម័តនូវ "*សេចក្តីប្រកាសសិទ្ធិរបស់មនុស្ស និងរបស់ប្រជាពលរដ្ឋ*" ដោយមានការជ្រោមជ្រែងពី ថូម៉ាស ជេហ្វឺសុន ដែលធានានូវសេរីភាព និងសិទ្ធិស្មើគ្នាចំពោះមនុស្សគ្រប់រូប។ គួរកត់សម្គាល់ផងដែរថា សិទ្ធិដែលបានចែងកាលពីជំនាន់នោះ ត្រូវបានប្រើប្រាស់មកដល់សព្វថ្ងៃនេះ ពោលគឺ `*សច្ចាធារណ៍នៃនិរទោស* ។[15]

ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ មានសន្ធិសញ្ញាអន្តរជាតិជាច្រើនដែលបានគាំពារកុមារ ជាក់ស្តែង អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ ១៩៨៩ បានកម្រិតឱ្យរដ្ឋភាគីធានាថាកុមារដែលមិនទាន់មានអាយុដល់ ១៥ ឆ្នាំនឹងមិនត្រូវចូលរួមក្នុងអរិភាព[16] និងបុគ្គលដែលមានអាយុតិចជាង ១៨ឆ្នាំ មិនត្រូវបានជ្រើសរើសឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធរបស់រដ្ឋជាដាច់ខាត ជាមួយគ្នានេះដែរ មិនត្រឹមតែអនុសញ្ញាស្តីពី សិទ្ធិកុមារប៉ុណ្ណោះទេ

---

[15] *សេចក្តីប្រកាសសិទ្ធិមនុស្ស និងរបស់ប្រជាពលរដ្ឋ នៃប្រទេសបារាំងឆ្នាំ១៧៨៩*, មាត្រា៤ និង; *កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*, មាត្រា១៤។

[16] អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩, មាត្រា៣៨។

ដែលគាំពារកុមារ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក៏បានការពារដោយប្រយោលក្នុងការពារតួយ៉ាងតម្រូវឱ្យកុមារសិទ្ធិទទួលបានការអប់រំ[១៧] សិទ្ធិសេរីភាពបុគ្គល និងទទួលបានការហូបចុកគ្រប់គ្រាន់ជាដើម។

### ១.២.៣. នីតិព្រហ្មទណ្ឌអន្តរជាតិ

នីតិព្រហ្មទណ្ឌអន្តរជាតិជាវិធានមួយនៃនីតិអន្តរជាតិដែលបង្កើតឡើង ដើម្បីកាត់ទោសបុគ្គលដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរទាំងឡាយ ដែលគំរាមកំហែងដល់សន្តិភាពសន្តិសុខ និងសុខមាលភាពពិភពលោក។[១៨] នីតិព្រហ្មទណ្ឌអន្តរជាតិមានការវិវត្តិយ៉ាងខ្លាំង ក្រោយពេលសង្គ្រាមលោកលើកទី២បានបញ្ចប់ ពោលគឺ បន្ទាប់ពីអាឡឺម៉ង់បានចាញ់សង្គ្រាម ក្រុមសម្ព័ន្ធមិត្តឈ្នះសង្គ្រាមរួមមាន បារាំង អាមេរិច សូវៀត និងអង់គ្លេសបានឈានដល់កិច្ចព្រមព្រៀងមួយ ដើម្បីបង្កើតតុលាការសម្រាប់ផ្តន្ទាទោសឧក្រិដ្ឋជនដែលបានបង្កវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ពិភពលោក។ ដូចនេះហើយនៅថ្ងៃទី ៨ សីហា ឆ្នាំ១៩៤៥ តុលាការយោធាអន្តរជាតិ Nuremberg នៅអាឡឺម៉ង់ ដែលមានវិធានធម្មនុញ្ញទីក្រុងឡុងដ៍ (London Charter) ជាវិធានគោលបានចែងនូវ អំពីបទល្មើសរួមមាន ឧក្រិដ្ឋកម្មនៃការឈ្លានពាន[១៩] (*Crime Against Peace*) ឧក្រិដ្ឋកម្មសង្គ្រាម[២០] និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។[២១]

មួយវិញដែរ ក្រោយមកអំឡុងឆ្នាំ១៩៩៣ មានសង្គ្រាមនៅអតីតយូហ្គោស្លាវី មានការសម្លាប់រង្គាលលើជនជាតិស៊ែប៊ី បាននាំឱ្យមានការបង្កើតតុលាការព្រហ្មទណ្ឌសម្រាប់អតីតយូហ្គោស្លាវីក្រោមការជួយជ្រោមជ្រែងពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។[២២] មិនតែប៉ុណ្ណោះ ក្រោយមកមួយឆ្នាំនៅប្រទេសរវ៉ាន់ដារមានការកាប់សម្លាប់គ្នារវាងរវាងក្រុមជនជាតិ Hutu និងTutsi ហើយក្លាយជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលនាំឱ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក្រោមការស្នើសុំពីរដ្ឋាភិបាលប្រទេសរវ៉ាន់ដារ សម្រេចបង្កើតតុលាការព្រហ្មទណ្ឌសម្រាប់រវ៉ាន់ដារ ដើម្បីកាត់ទោសឧក្រិដ្ឋជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិដូចជា

---

[១៧] *កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*, មាត្រា ២៤ និង *កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* , មាត្រា១៣ និង១៤។

[១៨] *បុព្វកថា* នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ១៩៩៨។

[១៩] វិធានធម្មនុញ្ញទីក្រុងឡុងដ៍, មាត្រា ៦(ក) *រកបានលើគេហទំព័រ* https://www.un.org/en/genocideprevention/documents/atrocity-crimes/Doc.2_Charter%20of%20IMT%201945.pdf

[២០] វិធានធម្មនុញ្ញទីក្រុងឡុងដ៍, មាត្រា ៦(ខ)

[២១] វិធានធម្មនុញ្ញទីក្រុងឡុងដ៍, មាត្រា ៦(គ)

[២២] *សូមមើល* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌសម្រាប់អតីតយូហ្គោស្លាវី, ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ១៩៩៣, ទំព័រ ១៤២, *រកបានលើគេហទំព័រ* *https://main.un.org/securitycouncil/sites/default/files/en/sc/repertoire/93-95/93-95_05.pdf#page=40*

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។[២៣] គួរកត់សម្គាល់ផងដែរថា តុលាការព្រហ្មទណ្ឌទាំងពីរនេះក៏បានបញ្ជាក់ ផងដែរអំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនូវអនុសញ្ញាក្រុងហ្សឺណែវ ១៩៤៩ ក្នុងជម្លោះប្រដាប់អាវុធ ដែលមានលក្ខណៈជាអន្តរជាតិ។[២៤] បន្ថែមពីលើនេះ ការជ្រើសរើសយកកុមារមកចូលធ្វើជាទាហាន នៅក្នុងជម្លោះប្រដាប់អាវុធគឺជាផ្នែកមួយនៃការរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិដែរដោយហេតុថាកុមារភាគច្រើនរងគ្រោះដោយសារសង្គ្រាម ដោយត្រូវបានគេបង្ខំឱ្យធ្វើការដែលពាក់ព័ន្ធនិងសង្គ្រាម និងជាពិសេសកុមារីដែលត្រូវបានគេរំលោភបំពានផ្លូវភេទផងដែរ។[២៥] មិនតែប៉ុណ្ណោះ កុមារជាទូទៅរមែងតែងតែទទួលបានការការពារជាមូលដ្ឋានពីវិធានច្បាប់អន្តរជាតិដទៃទៀតដូចជាអនុសញ្ញាស្តីពីសិទ្ធិកុមារ។[២៦]

បន្ថែមពីលើនេះទៀតនោះ លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ បានចែងនៅក្នុងមាត្រា ៨ (២) (ខ) (២៦) និង ៨ (២) (ង) (៧) បានហាមមិនឱ្យកុមារដែលមានអាយុក្រោម ១៥ឆ្នាំ មកចូលរួមក្នុងកងកម្លាំងប្រដាប់អាវុធ ឬក្រុមឧទ្ទាម ឬចូលរួមក្នុងសង្គ្រាមដោយផ្ទាល់ទេ ទោះបីជាជម្លោះប្រដាប់អាវុធនោះមានទម្រង់ជាអន្តរជាតិ ឬមិនមែនអន្តរជាតិក្តី។[២៧]

### ១.២.៤. អនុសញ្ញាស្តីពីសិទ្ធិកុមារ

អនុសញ្ញាស្តីពីសិទ្ធិជាគោលការណ៍បង្កើតមកដើម្បីការពារកុមារពីការបំពាន និងផ្តល់ការការពារនូវសិទ្ធិមួយចំនួនត្រូវការជាចាំបាច់ដែលជាសិទ្ធិអាទិភាព (ដោយគ្មានការរើសអើង សិទ្ធិទទួលបានការអប់រំ និងទទួលបានការចុះបញ្ជីអត្រានុកូលដ្ឋានភ្លាមៗបន្ទាប់ពីកើតជាដើម)។ អនុសញ្ញានេះត្រូវបានអនុម័តនៅឆ្នាំ ១៩៨៩ ដែលជាការបំពេញបន្ថែមនូវវិធាន ដែលមិនទាន់មាននិងធ្វើយ៉ាងណាឱ្យការការពារកុមារនៅលើសកលលោកនេះមានភាពទំលំទូលាយ។ បច្ចុប្បន្ននេះ អនុសញ្ញាស្តីពីសិទ្ធិកុមារមានរដ្ឋសមាជិក១៩៦ ដែលជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលត្រូវបានគេទទួលស្គាល់ជាងលិខិតបទដ្ឋានផ្សេងៗទៀត។[២៨]

---

[២៣] *សូមមើល* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌសម្រាប់រវ៉ាន់ដារ, ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤, ទំព័រ ១៤២, *រកបានលើគេហទំព័រ* https://main.un.org/securitycouncil/sites/default/files/en/sc/repertoire/93-95/93-95_05.pdf#page=41

[២៤] *សូមមើល* លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌសម្រាប់អតីតយូហ្គោស្លាវី, មាត្រា៣ និង *សូមមើល* David P. Steward, *International Criminal Law in a Nutshell*, 2nd ed., 2014, pp. 120-121.

[២៥] ពិធីសារបន្ថែមទី១ នៃអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៧៧, មាត្រា ៧៧ និង ៨៥(៥)។

[២៦] អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩, បុព្វកថា និងមាត្រា៣៨។

[២៧] លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ១៩៩៨, មាត្រា ៨។

[២៨] *សូមមើល* United Nations Treaty Collection, Convention on the Rights of the Child, New York, 20 November 1989; available at https://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-11&chapter=4&clang=_en.

អនុសញ្ញានេះបង្កើតមកដើម្បីការពារកុមារនិងធានាសិទ្ធិសេរីភាពរបស់កុមារជាមូលដ្ឋានដែលមានចាប់ការទទួលបាននូវការចុះក្នុងបញ្ជីអត្រានុកូលដ្ឋាន និងទទួលបានសញ្ជាតិ[២៩] រហូតដល់ការសិក្សារៀនសូត្រ ដោយគ្មានការរើសអើងពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ដើមកំណើតជនជាតិជាដើម។[៣០] ជាមួយគ្នានោះដែរ ក្នុងក្របខណ្ឌទាក់ទងនឹងការការពារពីការចាប់ដោយបង្ខំមកធ្វើជាទាហានក៏ត្រូវបានហាមឃាត់ផងដែរ ដោយមាត្រា៣៨ នៃអនុសញ្ញានេះបានកំណត់ថា កុមារក្រោម ១៥ ឆ្នាំនឹងមិនត្រូវបានឱ្យចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនឡើយ រួមទាំងរដ្ឋមានកាតព្វកិច្ចត្រូវចាត់រាល់វិធានការដែលអាចធ្វើទៅបានដើម្បីធានាការពារនិងថែទាំកុមារដែលប៉ះពាល់ដោយជម្លោះប្រដាប់អាវុធ។[៣១]

ជាក់ស្តែង ពិធីសារជម្រើសតាមចិត្តនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនិងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធបានបង្កើតមក ដើម្បីការពារកុមារពីការចាប់យកមកឬ កេណ្ឌធ្វើជាទាហានក្នុងការចូលរួមកងកម្លាំងប្រដាប់អាវុធ ដោយបានចែងថា *"សមាជិកកងកម្លាំងប្រដាប់ អាវុធដែលមិនគ្រប់អាយុ ១៨ឆ្នាំ មិនត្រូវបានជ្រើសរើសឱ្យចូលកងកម្លាំងប្រដាប់អាវុធជាដាច់ខាត"*។[៣២]

### ១.២.៥. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (United Nations Security Council [UNSC]) មានតួនាទីជាអង្គភាព សំខាន់និងចម្បងមួយរបស់ពិភពលោក ក្នុងការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិរួមទាំងទទួលខុសត្រូវផ្សេងៗ ដែលមានគោលបំណង រក្សាស្ថិរភាព និងការដោះស្រាយជម្លោះនៅទូទាំងពិភពលោក។ តាមរយៈ បេសកកម្មរក្សាសន្តិភាព UNSC អនុញ្ញាតឱ្យធ្វើអន្តរាគមន៍នៅក្នុងតំបន់ដែលមានជម្លោះប្រដាប់អាវុធដើម្បីជំរុញឱ្យមានដំណោះស្រាយការទូត និងធ្វើឱ្យស្ថានការណ៍មានស្ថិរភាពឡើងវិញ។

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាអ្នកសម្រុះសម្រួល និងការចរចារដើម្បីដោះស្រាយវិវាទរវាងប្រជាជាតិនានា រួមជាមួយនឹងវិធានការ ដូចជាការដាក់ទណ្ឌកម្ម និងការហ៊ុមព័ទ្ធដើម្បីទប់ស្កាត់ការឈ្លានពាន និងគោរពច្បាប់អន្តរជាតិ។ លើសពីនេះទៀត UNSC មានសិទ្ធិអំណាចក្នុងការដាក់ទណ្ឌកម្មលើសកម្មភាពយោធានៅពេលចាំបាច់ ទាំងដើម្បីស្តារសន្តិភាព ឬឆ្លើយតបទៅនឹងការគំរាមកំហែងដល់សន្តិសុខ

---

[២៩] អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩, មាត្រា៧។

[៣០] អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩, មាត្រា២។

[៣១] អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩, មាត្រា២ ៣ និង៤។

[៣២] ពិធីសារជម្រើសតាមចិត្តទី១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធតាំងពីឆ្នាំ ២០០១, មាត្រា ១ និង ២។

ពិភពលោក។ ដោយសារបញ្ហានៃការចាប់យកកុមារដែលមានអាយុក្រោម ១៥ឆ្នាំ មកចូលក្នុងជម្លោះប្រដាប់អាវុធមានការរីករាលដាលយ៉ាងខ្លាំងនៅចុងសតវត្សទី២០ និងដើមសតវត្សទី ២១នេះ ក្រុមប្រឹក្សាសន្តិសុខ ដើម្បីការពារសុខមាលភាពពិភពលោក និងដើម្បីការពារដែលងាយរងគ្រោះ បានចេញនូវសេចក្តីសម្រេចមួយចំនួនដូចជា៖ សេចក្តីសម្រេចលេខ១២៦១ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ UNSC បានអនុម័តជាឯកច្ឆ័ន្ទនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ១៩៩៩ គឺជាសេចក្តីសម្រេចដ៏សំខាន់ដំបូងគេដែលដោះស្រាយបញ្ហាកុមារក្នុងជម្លោះប្រដាប់អាវុធ ជាពិសេសថ្កោលទោសការជ្រើសរើស និងការប្រើប្រាស់ទាហានកុមារ។[៣៣] សេចក្តីសម្រេចនេះបានបង្កើត ក្រោមរបាយការណ៍គួរឱ្យព្រួយបារម្ភដែលបង្ហាញថាកុមារប្រមាណជាង ៣00,000 នាក់ ខ្លះអាយុក្រោម ៧ ឆ្នាំបានចូលរួមក្នុងជម្លោះប្រដាប់អាវុធនៅក្នុងប្រទេសជាង ៣0 ដោយរាប់លាននាក់ទៀតទទួលរងពីផលប៉ះពាល់នៃសង្គ្រាម រួមទាំងការស្លាប់ និងការផ្លាស់ទីលំនៅដោយបង្ខំ។ យ៉ាងណាមិញសេចក្តីសម្រេចនេះបានថ្កោលទោសចំពោះការយកកុមារលើកុមារនៅក្នុងជម្លោះប្រដាប់អាវុធ រួមទាំងការជ្រើសរើសរបស់ពួកគេជាទាហាន និងបានទទួលស្គាល់ផលប៉ះពាល់រយៈពេលវែងនៃការអនុវត្តបែបនេះទៅលើសន្តិភាព និងសន្តិសុខ។

ជាមួយគ្នានេះដែរ នៅក្នុងសេចក្តីសម្រេចអង្គការសហប្រជាជាតិក៏បានជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ ប្រកាន់ខ្ជាប់នូវច្បាប់អន្តរជាតិ ជាពិសេស អនុសញ្ញាទីក្រុងហ្សឺណែវ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយសង្កត់ធ្ងន់លើតម្រូវការការពារកុមារពីអំពើហិង្សា ការចាប់ពង្រត់ និងការប្រើប្រាស់យោធា។ សេចក្តីសម្រេចនេះក៏បានអំពាវនាវឱ្យមានការការពារកុមារក្នុងអំឡុងពេលការចរចាសន្តិភាព រួមនិងការសម្របសម្រួលនៃការផ្តល់ជំនួយមនុស្សធម៌ដោយបញ្ជាក់ពីតួនាទីរបស់អង្គការនានាដូចជា UNICEF និង UNHCR ក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ។ បន្ថែមពីលើនេះ សេចក្តីសម្រេចនេះបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការរំសាយទាហានកុមារ និងបញ្ចូលពួកគេទៅក្នុងសង្គមធម្មតាវិញ ដោយជំរុញឱ្យមានការខិតខំប្រឹងប្រែងផ្នែកនយោបាយដើម្បីបញ្ចប់ការជ្រើសរើស និងការប្រើប្រាស់របស់ពួកគេនៅក្នុងអរិភាព។ បន្ទាប់ពីសេចក្តីសម្រេចលេខ ១២៦១ UNSC បានអនុម័តដំណោះស្រាយបន្ថែមដើម្បីពង្រឹងក្របខ័ណ្ឌការពារកុមារក្នុងជម្លោះប្រដាប់អាវុធ ដែលមានដូចជាសេចក្តីសម្រេចលេខ១៣១៤ ដែលផ្អែកលើសេចក្តីសម្រេចមុនដោយបង្កើតវិធានការគោលដៅបន្ថែមទៀតសម្រាប់ការការពារកុមារ។

[៣៣] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចុះថ្ងៃទី២៦ កក្កដា ២០០៥, គេហទំព័រ https://digitallibrary.un.org/record/278324?ln=en&v=pdf

នៅឆ្នាំ ២០០៥ សេចក្តីសម្រេចលេខ ១៦១២ បានដាក់ចេញនូវយន្តការតាមដាន និងរាយការណ៍ ដើម្បីតាមដានការរំលោភលើកុមារក្នុងជម្លោះប្រដាប់អាវុធ រួមទាំងការជ្រើសរើសទាហានកុមារ ដែលមានសារៈសំខាន់ក្នុងការចងក្រងឯកសារការរំលោភបំពាន និងការធ្វើឱ្យអ្នកបំពានមានការទទួលខុសត្រូវ រួមចំណែកដល់កិច្ចខិតខំប្រឹងប្រែង និងសហប្រតិបត្តិការអន្តរជាតិឱ្យកាន់តែទូលំទូលាយ ដើម្បីឈានដល់ការលុបបំបាត់ការកេណ្ឌ និងប្រើប្រាស់ទាហានកុមារនៅលើសកលលោក។[៣៤]

## ១.៣. ទំនាក់ទំនងឧក្រិដ្ឋកម្មសង្គ្រាម និងជម្លោះប្រដាប់អាវុធ

ឧក្រិដ្ឋកម្មសង្គ្រាម ជាបទល្មើសដែលមានចែងក្នុងមាត្រា៨ នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដល់ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិអនុវត្តក្នុងពេលមានសង្គ្រាម។ ហេតុនេះហើយបានជា ធាតុផ្សំនៃបទល្មើសក្នុងឧក្រិដ្ឋកម្មសង្គ្រាមនៃការចាប់យកកុមារមកធ្វើជាទាហានគឺ តម្រូវឱ្យមានការផ្សាភ្ជាប់ទង្វើល្មើស និងបានកើតឡើងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធដែលអន្តរជាតិ[៣៥] និងមិនមែនជាលក្ខណៈអន្តរជាតិ។[៣៦]

ហេតុអ្វីបានជាគេត្រូវតែ បញ្ជាក់ (prove) យ៉ាងដូច្នេះ?

ការបញ្ជាក់នេះជាតម្រូវការមួយ ដែលបានចែងនៅក្នុងធាតុផ្សំនៃបទល្មើសរបស់ឧក្រិដ្ឋកម្មសង្គ្រាមក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។[៣៧] តម្រូវការទំនាក់ទំនង គឺជាធាតុសំខាន់មួយក្នុងការបង្កើតការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលចំពោះឧក្រិដ្ឋកម្មសង្គ្រាមក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ព្រោះវាបង្កើតទំនាក់ទំនងរវាងការប្រព្រឹត្តរបស់បុគ្គល ឬក្រុមដែលបានរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ ក្នុងពេលមានសង្គ្រាម។ ការតម្រូវឱ្យបញ្ជាក់យ៉ាងដូចនេះដោយសារតែ ឧក្រិដ្ឋកម្មសង្គ្រាម អាចនឹងកើតឡើងបានក្នុងពេលដែលមានជម្លោះប្រដាប់អាវុធតែប៉ុណ្ណោះ ដែលខុសពីបទល្មើសអន្តរជាតិពីរផ្សេងទៀតគឺ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចកើតឡើងបានទោះបីជាមិនមានជម្លោះប្រដាប់អាវុធ ដូចជាក្នុងពេលដែលមិនមានសង្គ្រាម តែមានក្រុមមួយបានផ្លាស់ទីកុមារដែលជាក្រុមមួយ ឬ

[៣៤] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចុះថ្ងៃទី២៦ កក្កដា ២០០៥, គេហទំព័រ https://www.refworld.org/legal/resolution/unsc/2005/en/14889

[៣៥] ធាតុផ្សំនៃបទល្មើសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៨(២)(ខ)(២៥), ទំព័រ៣១។

[៣៦] ធាតុផ្សំនៃបទល្មើសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៨(២)(ង) (៧), ទំព័រ៣៩.

[៣៧] *សូមមើល* រឿងក្តីរដ្ឋអាជ្ញា តទល់នឹង ថូម៉ាស លូបាងហ្គា, ២៩ មករា ២០០៧, រឿងក្តីលេខ ICC-01/04-01/06, អត្ថបទទី២៨៦.

ជាតិសាសន៍មួយដែលជិតបានផុតពូជ ទៅក្រុមមួយផ្សេងដោយបង្ខំ ដែលនាំឱ្យពួកគេពេលដឹងក្ដីអាចនឹងភ្លេចជាតិសាសន៍ដើមរបស់ខ្លួនបាន។[៣៨]

ជាការពិតណាស់ យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងរឿងក្ដី រដ្ឋអាជ្ញា តទល់នឹង ប៉ែមបា (Bemba Gombo) បានកំណត់ថា ដើម្បីបញ្ជាក់ថាជាឧក្រិដ្ឋកម្មសង្គ្រាម បទល្មើសដែលត្រូវបានចោទប្រកាន់ត្រូវនោះត្រូវតែបានប្រព្រឹត្ត នៅក្នុងបរិបទនិងផ្សាភ្ជាប់ទាក់ទងនឹងជម្លោះប្រដាប់អាវុធ។[៣៩] យ៉ាងណាមិញ បើករណីដែលមិនមានសង្គ្រាមកើតឡើងនោះមិនអាចចោទ ក៏ដូចជាកម្រិតឱ្យបុគ្គលនោះទទួលខុសត្រូវព្រហ្មទណ្ឌបាននោះទេ។

[៣៨] លក្ខន្តិកៈទីក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ ១៩៩៨, មាត្រា ៦ (ង)។

[៣៩] *សូមមើល* រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង ប៉ែបបា, ២១ មិនា ២០១៦, រឿងក្ដីលេខ ICC-01/05-01/08, អត្ថបទទី១៤២ និង១៤៣ *រកបានលើគេហទំព័រ* https://www.legal-tools.org/doc/edb0cf/pdf/.

# ជំពូកទី២
# ការប្រើប្រាស់ទាហានកុមារ
# នៅក្នុងសង្គ្រាមជាក់ស្តែង

# ជំពូកទី២: ការប្រើប្រាស់ទាហានកុមារនៅក្នុងសង្គ្រាមជាក់ស្តែង

## ២.១. ទាហានកុមារអំឡុងពេលសង្គ្រាមលោកលើកទី២

### ២.១.១. ប្រទេសអាឡឺម៉ង់

សង្គ្រាមលោកលើកទី២ បានបង្កវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ពិភពលោកដែលបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធពាសពេញពិភពលោក។ ជាមួយគ្នានេះដែរ កំឡុងពេលសង្គ្រាមអ៊ីត្លែបានប្រមូលនិងកេណ្ឌយកកុមារមកធ្វើជាទាហានឱ្យខ្លួនដែលត្រូវបានជ្រើសរើសដោយគណបក្សណាស៊ីអាឡឺម៉ង់។[៤០] កុមារទាំងប្រុស ស្រី ដែលរស់នៅក្នុងសង្គមអាឡឺម៉ង់សម័យនោះត្រូវបានកេណ្ឌ និងចាប់បង្ខំឱ្យចូលជាទាហានហើយតម្រូវឱ្យកុមារទាំងនោះត្រូវតែជឿ និងស្មោះស្ម័គ្រលើពួកឃោធាណាស៊ីតែមួយគត់។[៤១] មិនតែប៉ុណ្ណោះ ទាហានក្មេងៗប្រុសស្រីទាំងអស់ត្រូវបានអ៊ីត្លែបណ្តុះឱ្យមានគំនិត ស្អប់ខ្ពើមជនជាតិជ្វីប ជាពិសេសទៅទៀតនោះទាហានកុមារទាំងអស់នេះជាផ្នែកមួយសំខាន់ដែលអាចចោទអាលឺម៉ង់សម្លាប់ជនជាតិជ្វីបជាច្រើនលាននាក់។[៤២]

សូមកត់សម្គាល់ផងដែរថា នៅអាឡឺម៉ង់ជំនាន់នោះ ការចាប់យកកុមារមកធ្វើជាទាហានមាន ការកើតឡើងជាគំហុក ពោលនៅចុងឆ្នាំ១៩៣២ មានចំនួន ១សែននាក់[៤៣] ក្រោយមកចុងឆ្នាំ ១៩៣៣ បានកើនឡើងដល់ ២លាន ៣ សែននាក់ ប៉ុណ្ណោះនៅឆ្នាំ ១៩៤០ ចំនួននេះបានកើនឡើងដល់ ៨លាននាក់។[៤៤]

### ២.១.២. ប្រទេសជប៉ុន

ជាមួយគ្នានេះដែរ ជប៉ុនក៏ជាតួអង្គមួយដ៏ធំនៅក្នុងសង្គ្រាមលោកលើកទី២ផងដែរ និងបានចុះចាញ់ដោយសារអាមេរិចទម្លាក់គ្រាប់បែកនុយក្លេអ៊ែរ ២ គ្រាប់ទេ ទើបសុខចិត្តចុះចាញ់។ រយៈពេល ៦ឆ្នាំ នៃសង្គ្រាមជប៉ុនបានគ្រប់គ្រងមួយផ្នែកធំនៅអាស៊ី ដោយសារទ័ពរបស់ខ្លួនមានចំនួនច្រើន និងខ្លាំងក្នុងនោះផងដែរក៏មានការចាប់យក កុមារមកធ្វើជាទាហានផងដែរ។ ជាការពិតណាស់ ក្នុងការត្រៀមខ្លួនពីការឈ្លានពានពីក្រុមសម្ព័ន្ធមិត្តទាហានជប៉ុន បានបណ្តុះបណ្តាលក្មេងៗឱ្យត្រៀមប្រយុទ្ធជាមួយក្រុមសម្ព័ន្ធមិត្ត ដែលអាវុធធ្វើមកពី ឬស្សី រួមមានលំពែង កាំបិត មិនតែប៉ុណ្ណោះ កុមារជប៉ុនខ្លះអាយុ១៧ឆ្នាំបានធ្វើជាអ្នកបើកយន្តហោះធ្វើអត្តឃាត

[៤០] *សូមមើល* David Rosen, *Child Soldiers in the Western Imagination*, ២០១៥, ទំព័រ ៧៧។

[៤១] ដូចលេខយោងខាងលើ

[៤២] ដូចលេខយោងខាងលើ

[៤៣] *សូមមើល* H.W. Koch, *The Hitler Youth: Origins and Development 1922-1945*, ២០០០, ទំព័រ៨៩។

[៤៤] *សូមមើល* Stachura, Peter, *Modern Germany: An Encyclopedia of History, People, and Culture 1871-1990*, ១៩៩៨, ទំព័រ៤៧៩។

Kamikaze មកលើក្រុមសម្ព័ន្ធមិត្ត។ ដោយសង្គ្រាមកាន់តែកើនរ ព្រះចៅអធិរាជ ជប៉ុនបានចល័តសិស្សដែលមានអាយុពី១៤-១៧ ឆ្នាំនៅកោះអូគីណាវ៉ា មកចូលរួមធ្វើសង្គ្រាម នៅសមរភូមិអូគីណាវ៉ា ( the battle of Okinawa)។

យ៉ាងណាមិញ ដោយសារតែក្រុមសម្ព័ន្ធមិត្តមានកម្លាំងខ្លាំងជាង ជប៉ុនក៏ត្រូវបានបរាជ័យតែទោះជាយ៉ាងណាក៏ដោយ ក្រោយចាញ់សង្គ្រាមនៅកោះអូគីណាវ៉ា ជប៉ុនបានបង្កើតច្បាប់ថ្មីដែល កម្រិតថាកុមារា និងកុមារីដែលមានអាយុចាប់ពី ១៥ឆ្នាំ ឡើងត្រូវតែមានកាតព្វកិច្ចចូលធ្វើជាទាហាន ដោយគ្មានលក្ខណ្ឌ ហើយបើប្រកែកនិងរត់គេចនឹងត្រូវមានទោស។ តែក្រោយមកច្បាប់នេះមិនត្រូវបានអនុវត្តឱ្យប្រើដើម្បីកុមារនោះទេ ដោយហេតុថាជប៉ុនត្រូវបានចាញ់សង្គ្រាមលោកលើកទី២។

## ២.២. ទាហានកុមារក្រោយសង្គ្រាមលោកលើកទី២

### ២.២.១. ក្នុងសតវត្សទី ២០

#### ២.២.១.១. របបកម្ពុជាប្រជាធិបតេយ្យ

របបកម្ពុជាប្រជាធិបតេយ្យ ឬភាគច្រើនត្រូវបានគេស្គាល់ថាជារបបខ្មែរក្រហមដែលជារបបកាប់សម្លាប់ប្រជាជនស្លូតត្រង់ស្លាប់អស់ជាងពីរលាននាក់ នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩។ ទាហាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យត្រូវបានគេដឹងថាមានភាពសាហាវឃោរឃៅដែលសម្លាប់ប្រជាជាតិខ្លួន ដែល ទាហានកាលជំនាន់នោះស្ម័គ្រស្មោះនឹងអង្គការ តែក្នុងនោះក៏មានកុមារបានចូលរួមផងដែរ។ ជាដំបូង ក្រុមខ្មែរក្រហមបានចាត់ទុកកុមារដែលមានវណ្ណៈទាប និងរស់នៅជនបទជាអ្នកបរិសុទ្ធដោយសារតែពួកគេមានភាពស្លូតត្រង់ និងរស់នៅជាមួយក្រុមខ្មែរក្រហមតាំងពីនៅក្នុងព្រៃនិងកុមារមកពីវណ្ណៈទាបនេះជាកម្លាំងស្នូលដែលអនុវត្តបដិវត្តន៍របស់ខ្លួន។[៤៥]

ជាមួយគ្នានេះផងដែរកុមារនៅសម័យខ្មែរក្រហមត្រូវបានអង្គការចាប់យកមកបម្រើការងារជាច្រើនដែលមានដូចជាការឱ្យធ្វើជាទាហាន ធ្វើការធ្ងន់ និងល្បាតជំនួសអង្គការ និងឃ្លាំមើលសត្រូវ។ មិនតែប៉ុណ្ណោះក៏មានកុមារខ្លះទៀតត្រូវបានអង្គការប្រើឱ្យដើរបង្កប់គ្រាប់មីន និងគ្រាប់បែកដាក់ស្តែងលោកអាគីរ៉ាដែលជាទាហានកុមារ

[៤៥] *សូមមើល* Péter klemensits, Ráchel Czirják, *Child Soldiers in Genocidal Regimes: The Cases of the Khmer Rouge and the Hutu Power*, ២០១៦, ទំព័រ២១៦.

ជំនាន់ខ្មែរក្រហមបានថ្លែងយ៉ាងដូច្នេះ។[៤៦] រួមជាមួយគ្នានេះដែរ កុមារបានប្រើឱ្យធ្វើជាកងឈ្លបដើម្បីយកការអំពីទាហានវៀតណាម រួមទាំងធ្វើជាឈ្លបផ្ទៃក្នុងនៃក្រុមសហករណ៍ផងដែរ។

កុមារជាច្រើនត្រូវបានឱ្យកាន់កាំភ្លើងរួមទាំងបានឱ្យចូលធ្វើជាទាហានជួរមុខ ដើម្បីធ្វើសង្គ្រាមទាំងដែលគ្មានកាយសម្បទាគ្រប់គ្រាប់ និងមិនមានការយល់ដឹងជ្រៅជ្រះ។ បន្ថែមពីលើនេះទៀតនោះ កុមារជាច្រើនបានឱ្យបរិហារ និងសម្លាប់ជនសង្ស័យដែលជាមនុស្សពេញវ័យរួមទាំងឪពុកម្ដាយរបស់ខ្លួនផងដែរ ក្រោយពេលដែលអង្គការបានចាត់ទុកថាជាសត្រូវរបស់អង្គការ។[៤៧]

### ២.២.១.២. ប្រទេសសៀរ៉ាឡេអូន

សៀរ៉ាឡេអូនជាប្រទេសមួយស្ថិតនៅក្នុងទ្វីបអាហ្វ្រិកខាងលិច និងបានជួបប្រទះនូវសង្គ្រាមស៊ីវិលដែលបានកើតឡើងដោយសារតែមានអំពើពុករលួយ ការជួញដូរត្បូងខុសច្បាប់ ការគ្រប់គ្រងរដ្ឋមិនបានល្អដោយសារតែគិតតែពីផលប្រយោជន៍ខ្លួន ដែលនាំឱ្យមានឱនភាពសេដ្ឋកិច្ច រួមទាំងការបំបិទសិទ្ធិសេរីភាពប្រជាពលរដ្ឋ។ មិនតែប៉ុណ្ណោះ ក្រោយចូលនិវត្តន៍ ប្រធានាធបតី (Siaka P. Steven) បានតែងតាំង កូនចៅរបស់ខ្លួន ឱ្យជាប្រធានាធិបតីបន្ទាប់ ដើម្បីរួចគេចពីការកាត់ទោសក្រោយមានការមានការប្តូររបបដឹកនាំនយោបាយ[៤៨] ហេតុនេះហើយ បាននាំឱ្យកើតមានសង្គ្រាមស៊ីវិលកាលជំនាន់នោះដែលបានសម្លាប់ប្រជាជនស្លូតត្រង់អស់ប្រមាណជា៧៥,០០០ នាក់ និងបង្ខំឱ្យមានការជម្លាសប្រជាជនជាបង្ខំប្រមាណជា ២លាន ៥សែននាក់ និងភៀសខ្លួនទៅក្រៅទៅតាមព្រំដែនជាង ៦សែននាក់។[៤៩]

ទន្ទឹមនឹងនេះដែរ បដិវត្តន៍រណសិរ្សរួបរួម (Revolutionary United Front [RUF]) បានចាប់បង្ខំ កុមារជាច្រើនពីគ្រួសារមកចូលបម្រើឱ្យកងទ័ពរបស់ខ្លួនដោយកេណ្ឌ និងប្រើឱ្យកុមារទាំងអស់នោះ ចូលរួមក្នុងការប្រយុទ្ធក្នុងសង្គ្រាម កាប់សម្លាប់ប្រជាជនស្លូតត្រង់ យកមកឱ្យការពារតំបន់រុករកត្បូងមានតម្លៃ។ មិនតែប៉ុណ្ណោះ សម្រាប់កុមារីវិញត្រូវបានចាប់យកមកបម្រើផ្លូវភេទជូនទាហានប្រុសៗ។ ជាមួយគ្នានេះដែរ ភាគច្រើននៃទាហាន

---

[៤៦] *សូមមើល* Asia Society, *The Incredible Journey of Aki Ra, Former Child Soldier*, 13 តុលា 2009; *រកបានលើគេហទំព័រ* https://asiasociety.org/incredible-journey-aki-ra-former-child-soldier.

[៤៧] *សូមមើល* OpenLearn, ១១ មិថុនា ២០២៤ *រកបានលើគេហទំព័រ* https://www.open.edu/openlearn/society-politics-law/children-and-violence-introductory-international-and-interdisciplinary-approach/content-section-4.3.2

[៤៨] *សូមមើល* George Klay Kie, *Civilians and Civil Wars in Africa: The Cases of Liberia, Sierra Leone, and Côte D'Ivoire*, Peace Research, ២០១៦, ទំព័រ២១៤ *រកបានលើគេហទំព័រ* https://www.jstor.org/stable/2638262.

[៤៩] ដូចលេខយោងខាងលើ, ទំព័រ២១៥

កុមារទាំងនេះមានអាយុចន្លោះចាប់ពី៨ដល់១៤ឆ្នាំ[៥០] ត្រូវបានគេបង្ខំឱ្យប្រើសារធាតុញៀនមុនពេលមានប្រតិបត្តិការ ដើម្បីធ្វើឱ្យកុមារទាំងនោះហ៊ានសម្លាប់មនុស្សស្លូតត្រង់រួមទាំងអាចភ្លេចឪពុកម្តាយបង្កើតរបស់ខ្លួនបានផងដែរ។[៥១]

បន្ថែមពីលើនេះទៀតនោះ កុមារីមួយចំនួនបានរងការបំពានផ្លូវភេទយ៉ាងធ្ងន់ធ្ងរ តួយ៉ាងអតីតទាហានកុមារបានផ្តល់ការសម្ភាសន៍ជាអនាមិក ថា "*មេបញ្ជាការរបស់ខ្ញុំបានចាប់ក្មេងស្រីជំទង់ម្នាក់ ជាមួយនឹងប្អូនស្រីតូច (ទារក) និងម្តាយរបស់នាង។ គាត់បានបាញ់ម្តាយ និងប្អូនតូចរបស់នាងស្លាប់ ហើយគាត់បានទុកក្មេងស្រីជំទង់នោះឱ្យនៅរស់ ប៉ុន្តែគាត់បានប្រាប់នាងឱ្យដោះសំលៀកបំពាក់ចេញ ហើយគាត់រំលោភនាងតែម្តង*"។[៥២]

មិនតែប៉ុណ្ណោះ ការកេណ្ឌយកកុមារមកធ្វើជាទាហានកុមារនេះទៀតសោត ត្រូវបានតុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន ("Special Court for Sierra Leone") ចាត់ទុកថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានចែងនៅត្រង់មាត្រា ៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌ អន្តរជាតិ។[៥៣] ក្នុងនោះដែរ តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូនបានសម្គាល់ថា មុនឆ្នាំ ១៩៩៦ មានប្រទេស ១៨៥ បានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូចនេះវា បានបំពេញនូវធាតុផ្សំពីរគឺ ការអនុវត្តទូទៅ (State practice) និងការទទួលស្គាល់ដូចជាច្បាប់ (Opinio juris) ដោយមិនគិតពីប្រភេទនៃជម្លោះប្រដាប់អាវុធទោះបីជាអន្តរជាតិក្តី ឬមិនមែនអន្តរជាតិក្តី។[៥៤] ដូចនេះទោះបីជាប្រទេសសៀរ៉ាឡេអូនមិនមែនជាសមាជិកក្តី និងមួយវិញទៀតនិយាយជាសកលទោះបីជារដ្ឋដែលបានកេណ្ឌ និងចាប់យកកុមារមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ក្តីក៏វិធានហាមប្រាមមិនឱ្យកេណ្ឌ និងប្រើប្រាស់កុមារនៅតែអាចអនុវត្តបានផងដែរ។

---

[៥០] *សូមមើល* Alfred Zack-Williams, *Child Soldiers in the Civil War in Sierra Leone*, ២០០១, ទំព័រ ៧៤; *រកបានលើគេហទំព័រ* https://www.jstor.org/stable/4006694.

[៥១] *សូមមើល* Jacob Vellaccio, *The Revolutionary United Front and Child Soldiers During Sierra Leone's Civil War*, Thesis Report, Kansas, ២០១៥, ទំព័រ៦៥.

[៥២] *សូមមើល* Myriam Denov, *Coping with the trauma of war: Former child soldiers in post-conflict Sierra Leone*, 2010, ទំព័រ ៧៩៤ *រកបានលើគេហទំព័រ* https://doi.org/10.1177/0020872809358400.

[៥៣] លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ, មាត្រា ៣៨។

[៥៤] *សូមមើល* តុលាការសម្រាប់សៅ៉ាឡេអូន ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់ជាមួយនឹង សេម ហ៊ីងណា ណរម៉េន (Sam Hinga Norman), ថ្ងៃទី៣១ មេសា ២០០៤, អត្ថបទទី១៨។

### ២.២.១.៣. ប្រទេសអ៊ូហ្កាន់ដា

នៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ មានក្រុម Lord's Resistance Army (LRA) បានបង្កើតឡើងក្នុងគោលបំណងបះបោរប្រឆាំងនឹងរដ្ឋាភិបាលអ៊ូហ្កាន់ដា អស្ថិរភាពនយោបាយ និងភាពតានតឹងក្នុងតំបន់បន្ទាប់ពីការឡើងកាន់អំណាចរបស់ប្រធានាធិបតី Yoweri Museveni ក្នុងឆ្នាំ ១៩៨៦ ដោយសំបូរដោយអំពើពុករលួយ ការរំលោភសិទ្ធិមនុស្ស។ ក្នុងនោះដែរ ក្រុម LRA ត្រូវបានដឹកនាំដោយ Joseph Kony និងក្នុងសកម្មភាពដឹកនាំរបស់គាត់ដើម្បីប្រឆាំងនឹងកងទ័ពរដ្ឋាភិបាលអ៊ូហ្កាន់ដា គាត់បានចាប់យកកុមារមកធ្វើជាទាហានដើម្បីធ្វើជាទាហានជំនួយ។ ក្នុងរយៈពេល ១៦ឆ្នាំ ពោលគឺចាប់ពីឆ្នាំ ១៩៨៨ ដល់ ២០០៤ ក្រុមរបស់លោក Joseph Kony បានចាប់កុមារអ៊ូហ្កាន់ដា ជាង ៣០,០០០នាក់ មកធ្វើជាទាហានកុមារនៅសាលារៀន[៥៥] និងបានទៅចាប់យកដល់ក្នុងផ្ទះរួមទាំងសម្លាប់ឪពុកម្តាយកុមារផងដែរ។[៥៦]

កុមារទាំងនេះត្រូវបានទទួលការហ្វឹកហ្វឺន និងលត់ដំខាងយោធា ពង្វក់ឥតយ៉ាងធ្ងន់ធ្ងរ និងត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើហឹង្សាលើជនស្លូតត្រង់។ ក្មេងស្រីត្រូវបានបង្ខំឱ្យរៀបការ និងបង្កើតកូន ខណៈដែលក្មេងប្រុសបានឱ្យធ្វើជាទាហានជួរមុខ។ ជាមួយគ្នានេះដែរ អំពើហឹង្សាកើតឡើងឥតឈប់ឈរ ជាក់ស្តែងនៅពេលដែលកុមារបំពេញការងាររបស់ខ្លួនមិនបានល្អ ពួកគេត្រូវបានគេចាប់ចងវាយនឹងរំពាត់រហូតដល់ស្លាប់។[៥៧] ទន្ទឹមនឹងការពង្វក់និងការគំរាមកំហែងនេះហើយធ្វើឱ្យកុមារហ៊ានសម្លាប់ឪពុកម្តាយ និងសាច់ញាតិរបស់ខ្លួន។

ក្រោយបន្ទាប់ពីលោក Joseph Kony ត្រូវបានតុលាការព្រហ្មទណ្ឌអន្តរជាតិចេញដីការបង្គាប់ឱ្យចាប់ខ្លួននៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៥[៥៨] មានកុមារជាច្រើនត្រូវបានឱ្យចូលក្នុងសង្គមវិញ ដោយខ្លះបានរងខាងផ្លូវវិបត្តិស្មារតី និងត្រូវបានយកមកស្តារនីតិសម្បទា។ ទោះជាយ៉ាងណាក៏ដោយ កុមារដែលធ្លាប់ត្រូវបានគេចាប់

---

[៥៥] *សូមមើលគេហទំព័រ* https://worldhelp.net/the-tragic-history-of-ugandas-child-soldiers/; *សូមមើលគេហទំព័រ* https://borgenproject.org/child-soldiers-in-uganda-history-facts/

[៥៦] *សូមមើល* Elias Biryabarema, *You chop her: Ugandan recalls brutal upbringing as LRA child soldier*, ថ្ងៃទី៤ កុម្ភៈ ឆ្នាំ ២០២១, *រកបានលើគេហទំព័រ* https://www.reuters.com/article/world/you-chop-her-ugandan-recalls-brutal-upbringing-as-lra-child-soldier-idUSKBN2A4240/.

[៥៧] *សូមមើលគេហទំព័រ* https://smallwarsjournal.com/jrnl/art/youth-lost-ugandan-child-soldiers-in-the-lord%E2%80%99s-resistance-army

[៥៨] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង ចូសែប កូនី, ដីការសម្រេចឱ្យចាប់ខ្លួនចុះថ្ងៃទី ៨ កក្កដា ២០០៥ *រកបានលើគេហទំព័រ* https://www.icc-cpi.int/court-record/icc-02/04-01/05-53.

យកមកធ្វើជាទាហានភាគច្រើនមាន ជំងឺស្រ្តេសក្រោយការប៉ះទង្គិចផ្លូវចិត្ត (PTSD) ធ្ងន់ធ្ងរ និងជំងឺបាក់ទឹកចិត្ត ដោយសារហេតុថាអាក្រក់ដែលពួកគេបានជួបអំឡុងពេលនៅធ្វើជាទាហានកុមារ។

អង្គការ UNICEF និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតដូចជា Invisible Children និង World Help បានជួយជ្រុមជ្រែង ការពារកុមារនៅភាគខាងជើងប្រទេសអ៊ូហ្គង់ដា ដែលបានផ្តល់ការអប់រំ និងសេវាថែទាំសុខភាព និងគាំទ្រធ្វើសមាហរកម្មអតីតទាហានកុមារចូលក្នុងសង្គមឡើងវិញ។ មិនតែប៉ុណ្ណោះ ដើម្បីសម្រួលអតីតទាហានកុមារក្នុងការចូលក្នុងសង្គមវិញ កិច្ចព្រមព្រៀងសន្តិភាពស្តីពីការលើកលែងទោសមួយត្រូវបានបង្កើតឡើង ដោយផ្តល់ការលើកលែងទោសដល់ទាហានកុមារ។[៥៩]

## ២.២.២. ដើមសតវត្សទី ២១

### ២.២.២.១. សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ

សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ជារដ្ឋមួយនៅក្នុងទ្វីបអាហ្វ្រិក ដែលមានភាពវឹកវរ តាំងពីក្រោយទទួលបានឯករាជ្យ ហើយ ៣ទសវត្សចុងក្រោយនេះប្រទេសនេះបានជួប ប្រទះនូវផលប៉ះពាល់ និងវិនាសកម្មយ៉ាងខ្លាំងដែលក្នុងនោះមានប្រជាជនជាង ៥លាន នាក់បានស្លាប់ ដែលត្រូវបានគេហៅម្យ៉ាងទៀតថាជាសង្រ្គាមលោកនៅទ្វីបអាហ្វ្រិក។[៦០] យ៉ាងណាមិញ ចាប់តាំងពីឆ្នាំ២០០៣ មកកុមារដែលរស់នៅប្រទេសនេះតែងតែត្រូវបាន ក្រុមឧទ្ទាមបានកេណ្ឌមកធ្វើជាកងកម្លាំងបម្រើឱ្យខ្លួន និងការពារមេក្រុមនោះទៅវិញដែលភាគច្រើននៅភាគខាងកើតប្រទេស។[៦១]

គួររំលឹកផងដែរថា សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោបានផ្តល់សច្ចាប័នលើពិធីសារជម្រើសទី១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធតាំងពីឆ្នាំ ២០០១ តែការអនុវត្តច្បាប់នៅក្នុងប្រទេសមិនមានការរីកចម្រើននោះទេ ផ្ទុយទៅវិញមានតែការកេណ្ឌយកកុមារដែល មានអាយុក្រោម ១០

[៥៩] គេហទំព័ររបស់ គណៈកម្មការកាកបាទក្រហមអន្តរជាតិ (International Committee of the Red Cross), National Practice, Uganda, The Amnesty Act, ២០០០, *រកបានលើគេហទំព័រ* https://ihl-databases.icrc.org/en/national-practice/amnesty-act-2000-0.

[៦០] *គេហទំព័រ* Global Conflict Tracker, *Conflict in the Democratic Republic of Congo*, By the Center for Preventive Action, 20 June 2024, ចូលទស្សនា ២៦ មិថុនា ២០២៤ *រកបានលើគេហទំព័រ* https://www.cfr.org/global-conflict-tracker/conflict/violence-democratic-republic-congo.

[៦១] *សូមមើលគេហទំព័រ* https://www.warchild.net/documents/58/Tug-Of-War_Children_in_Armed_Groups_in_DRC.pdf.

ឆ្នាំ។ បើតាមការចុះផ្សាយរបស់ WITNESS[៦២] កុមារដែលមានអាយុត្រឹមតែ៦ឆ្នាំ ជារឿយៗត្រូវបានការចាប់យកមកធ្វើជាទាហាននិងបង្ហាត់បង្រៀនឱ្យចេះកាន់កាំភ្លើងនិងអាចសម្លាប់មនុស្សបាន។

ជាមួយគ្នានេះដែរ កុមារដែលត្រូវបានចាប់យកមកភាគច្រើនត្រូវបានគេបង្ខំឱ្យទៅធ្វើជាចារកិច្ច ឬអ្នកនាំសារសម្រាប់ក្រុមប្រដាប់អាវុធ ដោយសារពួកគេមិនងាយនឹងមានគេចាប់អារម្មណ៍ និងមានសមត្ថភាពក្នុងការផ្លាស់ទីដោយមិនមាននរណាកត់សម្គាល់ ដែលជាហេតុនាំឱ្យពួកគេប្រមូលការណ៍សម្ងាត់ និងចូលទៅក្នុងជំរុំសត្រូវដោយមិនមានការសង្ស័យ។ ទន្ទឹមនឹងនេះទៀតនោះ កុមារជាច្រើនត្រូវទទួលរងនូវពលកម្មដោយបង្ខំដែលអាចរួមបញ្ចូលការកាន់ឧបករណ៍ធុនធ្ងន់ បំពេញការងារដឹកជញ្ជូន ឬធ្វើការនៅក្នុងអណ្តូងរ៉ែដែលសម្បូរទៅដោយសារធាតុរ៉ែ និងមិនមានខ្យល់អុកស៊ីសែនគ្រប់គ្រាន់។ មួយវិញដែរ ការរំលោភបំពានផ្លូវភេទគឺជាបញ្ហាមួយផ្សេងទៀតនៅកុងហ្គោ ជាពិសេសក្មេងស្រីៗត្រូវបានគេសម្គាល់ឃើញថាងាយរងគ្រោះ ដែលត្រូវបានឱ្យធ្វើជាទាសករផ្លូវភេទ។ ក្រុមប្រដាប់អាវុធតែងតែប្រើអំពើហិង្សាចាប់ពង្រត់ក្មេងស្រី និងបង្ខំពួកគេឱ្យបម្រើផ្លូវភេទ។ ការណ៍នេះបានបន្សល់ទុកនូវការប៉ះពាល់ដល់ផ្លូវចិត្តយ៉ាងខ្លាំង ហើយអាចនាំទៅរកការមានផ្ទៃពោះដែលមិនចង់បាន ការឆ្លងជំងឺកាមរោគ និងការមាក់ងាយក្នុងសង្គមនៅពេលពួកគេត្រឡប់ទៅក្នុងសង្គមធម្មតាវិញ។

យ៉ាងណាមិញ ក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga កាលពីឆ្នាំ ២០០៦ តុលាការព្រហ្មទណ្ឌអន្តរជាតិបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន Thomas Lubanga ដែលបានប្រព្រឹត្តនូវបទល្មើសនៃការចាប់យកកុមារមកចូលរួមក្នុងកងកម្លាំងប្រដាប់អាវុធដែលបានប្រព្រឹត្តនៅចន្លោះ ខែកក្កដា ឆ្នាំ២០០២ ដល់ ខែធ្នូ ឆ្នាំ ២០០៣។[៦៣] នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ គាត់ត្រូវបានតុលាការសម្រេចកាត់ទោសជាប់ពន្ធនាគារចំនួន ១៤ ឆ្នាំ ចំពោះឧក្រិដ្ឋកម្មនៃការចាប់យកកុមារ រួមនិងបទល្មើសផ្សេងៗទៀត ដែលត្រូវបានបញ្ជូនមកកាន់ប្រទេសរបស់គាត់ដើម្បីអនុវត្តទោស។[៦៤]

[៦២] *សូមមើលគេហទំព័រ* https://www.witness.org/portfolio_page/protecting-child-soldiers-democratic-republic-congo/

[៦៣] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹងថូម៉ាស លូបាងហ្គា, ដីកាបង្គាប់ឱ្យចាប់ខ្លួនចុះថ្ងៃទី ១០ កុម្ភៈ ២០០៦, ទំព័រ៣; *រកបានលើគេហទំព័រ* https://www.icc-cpi.int/sites/default/files/CourtRecords/CR2006_02234.PDF.

[៦៤] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹងថូម៉ាស លូបាងហ្គា, កក្កដា ២០២១; *រកបានលើគេហទំព័រ* https://www.icc-cpi.int/sites/default/files/CaseInformationSheets/LubangaEng.pdf.

### ២.២.២.២. ប្រទេសយេម៉ែន

នៅប្រទេសយេម៉ែន កុមារងាយរងគ្រោះនិងបានប្រឈមនឹងការចាប់យកមកធ្វើជាទាហានចាប់តាំងពីឆ្នាំ២០០៤ តែក្រោយមកមានការកើតឡើងយ៉ាងគួរឱ្យកត់សម្គាល់ក្រោយពេលដែលក្រុម Houthi បានធ្វើរដ្ឋប្រហាររដ្ឋាភិបាលស្របច្បាប់នៅឆ្នាំ២០១៤។ ចាប់តាំងពីក្រោយរដ្ឋប្រហារនេះមក ក្រុមឧទ្ទាមដែលបានដឹកនាំប្រទេសបានចាប់យកកុមារជាច្រើនមកធ្វើជាទាហានរបស់ខ្លួន ដើម្បីឱ្យកុមារទាំងនោះប្រយុទ្ធជាមួយក្រុមសត្រូវ ដែលមានទំនោរទៅរករដ្ឋាភិបាលយេម៉ែន ដោយហេតុថាស្ថានភាពសេដ្ឋកិច្ចនៅប្រទេសយេម៉ែនមិនសូវល្អ ភាពក្រីក្រនៅក្នុងសង្គម កុមារងាយស្រួលក្នុងការលួងលោម។ ត្រឹមចុងឆ្នាំ២០២២ អង្គការ UNICEF បានប៉ាន់ប្រមាណថាកុមារជា ៣៩៩៥នាក់ ត្រូវបានយកមកចូលរួមក្នុងជម្លោះប្រដាប់អាវុធ រួមទាំងរបួសនិងស្លាប់ជិត ១០០០០នាក់។[៦៥]

ថ្មីៗនេះ កាលសង្គ្រាមនៅហ្គាសាបានផ្ទុះឡើង នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ ក្រុម Houthi បានបន្តការយកកុមារមកចូលក្នុងជម្លោះប្រដាប់អាវុធដោយបានប្រកាសជាសាធារណៈថានឹងជួយប៉ាលេស្ទីន ដែលក្នុងនោះមានកុមាររាប់ពាន់នាក់ត្រូវបានគេដាក់បញ្ចូកជាទាហានដើម្បីចូលធ្វើសង្គ្រាម។ បន្ថែមពីលើនេះទៀតនោះ Human Rights Watch បានបន្ថែមថា កុមារដែលបានកេណ្ឌមកធ្វើជាទាហាននោះមានអាយុក្រោម ១៨ឆ្នាំច្រើននិងខ្លះមានអាយុត្រឹមតែ១៣ឆ្នាំនោះទេ។[៦៦] យ៉ាងណាមិញក្រៅពីការចូលធ្វើជាទាហានជួរមុខនៅក្នុងជម្លោះប្រដាប់អាវុធ កុមារក៏ត្រូវបានបង្ខំឱ្យបម្រើក្នុងផ្នែកផ្សេងៗទៀតដូចជា អ្នកនាំសារ អ្នកបង្កប់គ្រាប់មីនដែលតួនាទីនេះអាចបង្កគ្រោះថ្នាក់ដល់ពួកគេដោយហេតុថាពេលខ្លះអាចត្រូវគេចាប់បាននិងធ្វើទារុណកម្ម និងអំពើហឹង្សាផ្សេងៗ។[៦៧]

### ២.២.២.៣. ប្រទេសស៊ូដង់ខាងត្បូង

ស៊ូដង់ខាងត្បូងជាប្រទេសដែលទើបនឹងទទួលបានឯករាជ្យពីស៊ូដង់ ជាប្រទេសថ្មីនៅឆ្នាំ ២០១១ នេះទេដែលមុននោះប្រទេសទាំងពីរនេះធ្លាប់មានសង្គ្រាមស៊ីវិលជាមួយគ្នាដោយសារតែមានបញ្ហាជាតិសាសន៍

---

[៦៥] *សូមមើលគេហទំព័រ* https://www.unicef.org/mena/press-releases/more-11000-children-killed-or-injured-yemen

[៦៦] *សូមមើលគេហទំព័រ* https://www.hrw.org/news/2024/02/13/yemen-houthis-recruit-more-child-soldiers-october-7

[៦៧] *សូមមើលគេហទំព័រ* Amnesty International, *Yemen: Huthi forces recruiting child soldiers for front-line combat*, ថ្ងៃទី ២៨ កុម្ភៈ ២០១៧, *រកបានលើគេហទំព័រ* https://www.amnesty.org/en/latest/press-release/2017/02/yemen-huthi-forces-recruiting-child-soldiers-for-front-line-combat/.

និងបរិបទ នៃការដឹកនាំប្រទេសខុសគ្នារវាងស៊ូដង់ខាងត្បូង និងស៊ូដង់។ ជាមួយគ្នានេះដែរ កុមារត្រូវបានគេសម្គាល់ឃើញ ថាបានចូលរួមយ៉ាងសកម្មនៅក្នុងជម្លោះប្រដាប់អាវុធនៅស៊ូដង់ខាងត្បូងប្រមាណជា ១៩០០០ នាក់ នៅឆ្នាំ ២០១៣ ដែលចំនួននេះច្រើន ដែលបានប៉ាន់ប្រមាណដោយក្រសួងការបរទេសសហរដ្ឋអាមេរិក។[៦៨] សូមកត់ សម្គាល់ផងដែរថា ស៊ូដង់ខាងត្បូងក៏មានច្បាប់ស្ដីពីហាមប្រាមមិនឱ្យយកកុមារមកចូលក្នុងការធ្វើសង្គ្រាមផងដែរ ពោលគឺ កុមារគ្រប់រូបដែលមានអាយុក្រោម ១៨ ឆ្នាំមិនត្រូវបានតម្រូវឱ្យបម្រើក្នុងជួរកងទ័ពទេ តែការអនុវត្តមិន សូវមានប្រសិទ្ធិភាពទេដោយសារតែប្រព័ន្ធយុត្តិធម៌ និងស្ថានភាពសង្គ្រាមនៅតែរីករាល។

ជាក់ស្តែង របាយការណ៍របស់ Human Rights Watch[៦៩] បានបញ្ជាក់ថាមិនមែនត្រឹមតែក្រុមឧទ្ទាមទេ ដែលបានប្រើកុមារមកធ្វើជាទាហានក្នុងនោះដែរ ខាងរដ្ឋាភិបាលក៏បានយកកុមារមកធ្វើជាទាហាន ដើម្បីជួយធ្វើសង្គ្រាមផងដែរ។ កុមារដែលរស់នៅជនបទ និងរស់នៅក្រៅតំបន់ការពារសន្តិសុខរបស់កងរក្សាសន្តិសុខរបស់ អង្គការសហប្រជាតិ តែងតែត្រូវបានគេបង្ខំឱ្យចូលធ្វើទាហាន និងបើមិនធ្វើតាមពួកគេនឹងបានគេធ្វើបាប ដូចជា ត្រូវបានគេវាយធ្វើបាប និងអំពើទារុណកម្មផ្សេងទៀត។

ក្នុងនោះដែរ កុមារដែលត្រូវបានចាប់យកមកធ្វើជាទាហានដែល ពួកគេបាននិយាយថា ពួកគេរស់នៅរាប់ខែដោយមិនមានអាហារគ្រប់គ្រាន់ ឆ្ងាយពីគ្រួសារ ហើយត្រូវបានគេបោះចូលទៅក្នុងការប្រយុទ្ធគ្នាដោយកាំភ្លើងដ៏គួរឱ្យភ័យខ្លាច ដែលពួកគេបានរងរបួស និងបានឃើញមិត្តភក្តិដែលបានចូលរួមធ្វើទាហានជាមួយគ្នាត្រូវបានសម្លាប់។ រហូតមកដល់ពេលនេះ បុគ្គលដែលជាមេបញ្ជាការមិនទាន់ត្រូវបានកាត់ទោសនោះទេ តែក៏បានការទទួចពីប្រជាជន និងអង្គការក្រៅរដ្ឋាភិបាលឱ្យមានការបង្កើត Hybrid Court ដើម្បីកាត់ទោសលក្ខណៈជាអន្តរជាតិផងដែរ។[៧០]

---

[៦៨] *សូមមើល* របាយការណ៍របស់ក្រសួងការបរទេសហរដ្ឋអាមេរិចឆ្នាំ២០១៨ *រកបានលើគេហទំព័រ* https://www.state.gov/reports/2018-country-reports-on-human-rights-practices/south-sudan/.

[៦៩] *សូមមើលគេហទំព័រ* https://www.hrw.org/news/2015/12/14/south-sudan-terrifying-lives-child-soldiers

[៧០] *សូមមើលគេហទំព័រ* https://www.hrw.org/news/2015/12/14/south-sudan-terrifying-lives-child-soldiers

## ២.៣. ផលវិបាក

### ២.៣.១. ផលវិបាកដោយផ្ទាល់

អតីតទាហានកុមារក្រោយពេលត្រឡប់មកចូលក្នុងសង្គមវិញរមែងតែងតែជួបប្រទះនូវផលវិបាកដោយផ្ទាល់ដូចជា៖

១. គ្រោះថ្នាក់ដល់រាងកាយ៖ ភាគច្រើននៃអតីតទាហានកុមារតែងតែមានគ្រោះថ្នាក់ដល់រូបរាងកាយ ដោយហេតុថា ក្នុងពេលដែលជាទាហានត្រូវបានមេបញ្ជាការប្រើឱ្យធ្វើជាទាហានជួរមុខ និងរបួសដោយគ្រាប់កាំភ្លើង របួសគ្រាប់ផ្លោង និងការជាន់មីនជាដើម។ ជាមួយគ្នានេះដែរ ពួកគេពេលខ្លះក៏ជួបការធ្វើទារុណកម្មដើម្បីសួរចម្លើយ ដោយហេតុថាពួកគេត្រូវបានគេប្រើឱ្យមកស៊ើបការពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត។

២. បាត់បង់ការរៀនសូត្រ៖ កុមារត្រូវបានគេយកមកធ្វើជាទាហានទាំងដែលខ្លួននៅក្មេង ដែលជាវ័យត្រូវក្រេបយកចំណេះដឹង តែផ្ទុយមកវិញត្រូវចូលរួមក្នុងជម្លោះប្រដាប់អាវុធ ដែលខកខានក្នុងការរៀនសូត្រ និងសេវាដទៃទៀតដែលសង្គមផ្តល់ឱ្យ ដែលអាចជះឥទ្ធិពលដល់អនាគតរបស់ពួកគេ។

៣. ការមាក់ងាយ និងការរើសអើង ក្រោយពេលត្រឡប់ចូលក្នុងសង្គមវិញ៖ នេះជាបញ្ហាមួយដែលបានកើតឡើងមកលើទាហានកុមារណាដែលត្រូវបានគេបញ្ជាឱ្យសម្លាប់ និងធ្វើបានអ្នកដទៃ ដោយហេតុថាជនដែលត្រូវបានអតីតទាហាននោះធ្វើបាន និងមានការស្អប់ខ្ពើម ពីព្រោះតែអំពើដែលអតីតទាហាននោះធ្វើមកលើខ្លួន ទោះបីជាអតីតទាហាននោះធ្វើតាមការបញ្ជាក៏ដោយ។ មួយវិញទៀត គឺបញ្ហាបុគ្គលខ្លួនឯង សំអាងន័យថាខ្លួនធ្លាប់បានសម្លាប់ និងធ្វើបានប្រជាជនស្លូតត្រង់ នាំឱ្យមានការគិតថាអារម្មណ៍ថាឯកោ និងដាច់ឆ្ងាយពីមិត្តភក្តិ និងសហគមន៍របស់ពួកគេ។

៤. អំពើហឹង្សាបន្ត៖ ការកើតឡើងបន្តនេះកើតឡើងក្រោយពេលដែលកុមារបានរងការប៉ះពាល់ផ្លូវចិត្តយ៉ាងខ្លាំង។ ការប៉ះពាល់ផ្លូវចិត្តនេះអាចលេចចេញពីរបរិបទ ដែលបរិបទទី១ពួកគេភ្លាច និងមិនហ៊ានចូលក្នុងសង្គម និងបរិបទទី២គឺ ពួកគេអាចអាចនឹងមានគំនិតប្រព្រឹត្តនូវអំពើដូចគ្នានេះដែរ។ ជាក់ស្តែង Domonic Ongwen គាត់ត្រូវបានចាប់ធ្វើជាទាហាននៅពេលដែលគាត់ដើរទៅសាលារៀននៅឆ្នាំ ១៩៨៨ ក្នុងចន្លោះអាយុ ៩ ទៅ ១៤ឆ្នាំ។ Domonic Ongwen បានព្យាយាមរត់គេចខ្លួន ប៉ុន្តែត្រូវបានចាប់ខ្លួន និងទទួលទណ្ឌកម្មយ៉ាងឃោរឃៅ រួមទាំងត្រូវបានបង្ខំឱ្យកាត់ស្បែកអ្នកជាប់ឃុំម្នាក់ទៀត ជាការ

ព្រមានប្រឆាំងនឹងការប៉ុនប៉ងរត់គេច។[៧១] ក្រោយពីបានចូលជាទាហានកុមារ គាត់មិនមកចូលក្នុងសង្គមធ្វើជាជាធម្មតា តែផ្ទុយទៅវិញគាត់បានធ្វើជាទាហាន ដែលគាត់បានក្លាយជាមេបញ្ជាការនៃកងពលតូច Sinia ដែលជាកងពលតូចមួយក្នុងចំណោមកងពលតូចទាំងបួនរបស់ LRA ហើយបានដឹកនាំការវាយប្រហារជាច្រើនប្រឆាំងនឹងប្រជាជនស៊ីវិល និងប្រជាជនផ្លាស់ទីលំនៅ។ ក្នុងអំឡុងពេលនៃការវាយប្រហារទាំងនេះ មានករណីឃាតកម្ម ការប្លន់ ការរំលោភសេពសន្ថវៈ (បណ្តាលឱ្យមានផ្ទៃពោះដោយបង្ខំ) និងឧក្រិដ្ឋកម្មសង្គ្រាមផ្សេងទៀត។[៧២]

៥. ការប៉ះពាល់ដល់សុខភាព៖ ទាហានកុមារភាគច្រើនរស់នៅក្នុងជំរុំដែលដែលគ្មានអនាម័យ ដែលបង្កើនភាពងាយរងគ្រោះរបស់ពួកគេចំពោះជំងឺឆ្លង។ ដូចគ្នានេះដែរ កង្វះទឹកស្អាត អនាម័យមិនគ្រប់គ្រាន់ នាំឱ្យមានជំងឺដូចជា ជំងឺគ្រុនចាញ់ ជំងឺអាសន្នរោគ និងការឆ្លងមេរោគផ្លូវដង្ហើម។ កង្វះអាហារូបត្ថម្ភ ដែលជារឿងធម្មតាក្នុងចំណោមកុមារនៅក្នុងតំបន់ជម្លោះ ធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់ពួកគេចុះខ្សោយ ធ្វើឱ្យពួកគេងាយនឹងកើតជំងឺទាំងនេះ។ យ៉ាងណាមិញ នៅក្នុងជម្លោះខ្លះទាហានកុមារត្រូវបានបង្ខិតបង្ខំឱ្យប្រើប្រាស់គ្រឿងញៀន ដើម្បីធ្វើឱ្យពួកគេហ៊ានក្នុងការប្រយុទ្ធឬធ្វើឱ្យបាត់ការឈឺចាប់។[៧៣] មួយវិញទៀតចំពោះទាហានកុមារស្រីៗ ដែលងាយរងគ្រោះដោយអំពើហិង្សាផ្លូវភេទ ដែលអាចបណ្តាលឱ្យមានផ្ទៃពោះដោយការមិនចង់បាន ការកើតជំងឺអេដស៍ និងជំងឺកាមរោគផ្សេងទៀត។[៧៤]

### ២.៣.២. ផលវិបាកដោយប្រយោល

ទន្ទឹមនឹងការប៉ះពាល់ដោយផ្ទាល់ ក៏មានការប៉ះពាល់ដោយប្រយោលមកលើកុមារផងដែររួមមាន៖

១. របួសផ្លូវចិត្ត៖ សង្គ្រាមជាព្រឹត្តិការណ៍មួយដ៏អាក្រក់និងជិតដាមក្នុងអារម្មណ៍ ជាមួយគ្នានេះដែរអតីតទាហានកុមារតែងតែជួបនូវបញ្ហានេះ មានពេលខ្លះពួកគេបានឃើញនូវអំពើឃោរឃៅដែលមេបញ្ជាការ

---

[៧១] *សូមមើល* Daniel Bernard, *From Child Abductee to Rebel Commander: The Story Of Uganda's Dominic Ongwen*, ថ្ងៃទី៩ ខែមិនា ឆ្នាំ ២០២១ *រកបានលើគេហទំព័រ* https://humanglemedia.com/from-child-abductee-to-rebel-commander-the-story-of-ugandas-dominic-ongwen/.

[៧២] ដូចលេខយោងខាងលើ; *សូមមើល* Mark Kersten, *The Life and Times of Dominic Ongwen, Child Soldier and LRA Commander*, ថ្ងៃទី១២ មេសា ២០១២; *រកបានលើគេហទំព័រ* https://justiceinconflict.org/2016/04/12/the-life-and-times-of-dominic-ongwen-child-soldier-and-lra-commander/.

[៧៣] *សូមមើលគេហទំព័រ* https://sps.cuny.edu/focus-health-child-soldiers

[៧៤] *សូមមើល* Barry S. Levy, *The Impacts of War on Children's Health*, ខែមេសា ឆ្នាំ២០២៤, ទំព័រ ៨៤១–៨៥២; *រកបានលើគេហទំព័រ* https://doi.org/10.1093/oso/9780197662526.003.0063.

ឬក៏ទាហានដទៃទៀតបានសម្លាប់ឪពុកម្ដាយរបស់ពួកគេ សាច់ញាតិ និងការបៀតបៀនមកលើជនស៊ីវិលស្លូតត្រង់ ទន់ខ្សោយ យកក្មេងៗស្រីៗមកធ្វើការរំលោភ និងទារុណកម្មជាដើម។ ការណ៍ដែលឃើញហេតុការណ៍ទាំងអស់នេះអាចបណ្ដាលឱ្យមានរបួសផ្លូវចិត្តធ្ងន់ធ្ងរ ដូចជាជំងឺស្ត្រេសក្រោយការប៉ះទង្គិចផ្លូវចិត្ត (PTSD) ជំងឺធ្លាក់ទឹកចិត្ត ការថប់បារម្ភ និងបញ្ហាសុខភាពផ្លូវចិត្តផ្សេងទៀត រហូតដល់មានការធ្វើអត្តឃាត។

២. ការមិនអាចគ្រប់គ្រងខ្លួនបាន៖ អតីតទាហានកុមារភាគច្រើន រមែងតែងតែប្រើហឹង្សាដើម្បីដោះស្រាយជម្លោះដោយហេតុថាពួកគេបានបណ្ដុះឱ្យមានគំនិតកោងកាចពីក្មេង រួមទាំងគ្មានចំណេះដឹងគិតវែងឆ្ងាយផងដែរ។

៣. ការប៉ះពាល់ដល់សង្គមនិងគ្រួសារ៖ ទាហានកុមារប្រឈមមុខនឹងការរំខានខាងផ្នែកសង្គម និងគ្រួសារដែលជារឿយៗពួកគេបំបែកចេញពីគ្រួសារ បណ្ដាលឱ្យ ឱ្យពួកគេមានអារម្មណ៍ឯកោ អស់សង្ឃឹម និងបញ្ហាសុខភាពផ្លូវចិត្ត។ អតីតទាហានកុមារ ជាពិសេសអ្នកដែលកំព្រា ប្រឈមនឹងភាពងាយរងគ្រោះកាន់តែខ្លាំងឡើងចំពោះការកេងប្រវ័ញ្ច ពលកម្មដោយបង្ខំ ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ។ ក្រោយពេលដែលពួកគេត្រឡប់ចូលក្នុងសង្គមវិញ ពួកគេអាចនឹងគ្មានផ្ទះសម្បែង ឬរស់នៅក្នុងភាពក្រីក្រខ្លាំង ហើយអាចនាំឱ្យមានសកម្មភាពល្មើសណាមួយផ្សេងទៀត។

# ជំពូកទី ៣
# ដំណោះស្រាយបញ្ឈប់ការប្រើប្រាស់អាហារកុមារ

# ជំពូកទី៣: ដំណោះស្រាយបញ្ចប់ការប្រើប្រាស់ទាហានកុមារ

## ៣.១. ការកាត់ទោសរបស់តុលាការ ជាទម្រង់នៃការគាំពារទាហានកុមារ

### ៣.១.១. សាលក្រមរបស់តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន

ដើម្បីបញ្ឈប់នូវការជ្រើសរើស និងប្រើប្រាស់កុមារនៅក្នុងកងកម្លាំងប្រដាប់អាវុធក្នុងសង្គ្រាម ឬជម្លោះប្រដាប់អាវុធនានា អង្គការអន្តរជាតិបានរួមរួបគ្នាបង្កើតច្បាប់អន្តរជាតិ ក៏ដូចជា បង្កើតតុលាការ Ad Hoc និងតុលាការអចិន្ត្រៃយ៍ ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិជាដើម ដើម្បីកាត់ទោសលើមេដឹកនាំ ដែលបានប្រព្រឹត្តអំពើនេះ។ យើងឃើញមានការកាត់ទោសលើបទល្មើសនៃការប្រើប្រាស់ទាហានកុមារដំបូងគេនៅក្នុងតុលាការ Ad Hoc សម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") Special Court for Sierra Leone ដែលសេចក្តីសម្រេចទាំងនោះ មានសារៈសំខាន់ក្នុងការបកស្រាយច្បាប់ និងធាតុផ្សំនៃបទល្មើសនេះពីព្រោះនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ១៩៩៨ ក៏មានប្រើប្រាស់ពាក្យពេចន៍ និងធាតុផ្សំដូចគ្នានឹងលក្ខន្តិកៈស្តីពីតុលាការសម្រាប់សៀរ៉ាឡេអូនឆ្នាំ២០០២ ហេតុនេះការកាត់ទោសនៅក្នុងតុលាការ Ad Hoc សម្រាប់ប្រទេសសៀរ៉ាឡេអូន គឺដូចជាការសាកល្បងកាត់ទោសដោយប្រើប្រាស់បទល្មើសនេះក្រៅតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។[៧៥]

ករណីដំបូង ដែលត្រូវបានតុលាការកាត់ក្តីអំពីការប្រើប្រាស់កុមារក្នុងកងប្រដាប់អាវុធគឺ លោក Sam Hinga Norman (សេម ហេនហ្គា ន័រម៉ាន់) ដែលជារដ្ឋមន្ត្រីនៃក្រសួងមហាផ្ទៃរបស់សាធារណរដ្ឋសៀរ៉ាឡេអូនទាក់ទងនឹងសង្គ្រាមស៊ីវិលនៅប្រទេសសៀរ៉ាឡេអូន។[៧៦] ក្នុងដំណើរការនៃនីតិវិធី មេធាវីតំណាងលោក Sam Hinga Norman (សេម ហេនហ្គា ន័រម៉ាន់) បានច្រានចោលបទចោទដែលពាក់ព័ន្ធនឹងការជ្រើសរើសកុមារក្រោមអាយុ ១៥ឆ្នាំ ដោយហេតុផលថា ការជ្រើសរើសកុមារធ្វើជាទាហានមិនមែនជាបទល្មើសក្រោម ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០១ ដែលជាពេលដែលមានការប្រព្រឹត្តនោះកើតឡើងឡើយ។[៧៧] ទន្ទឹមនិងគ្នានេះដែរ មេធាវីតំណាងលោក Sam Hinga Norman (សេម ហេនហ្គា ន័រម៉ាន់) បានបន្តលើកឡើងថាច្បាប់អន្តរជាតិដូចជា ពិធីសារបន្ថែមទី២ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៧៧ និងអនុសញ្ញាស្តីពីសិទ្ធិកុមារបានហាមឃាត់អំពីការជ្រើសរើសកុមារជាទាហានក៏ពិតមែន ប៉ុន្តែពិធីសារ និងអនុសញ្ញានេះគឺមិនទាន់កំណត់ថា

---

[៧៥] *សូមមើល* Julie McBride, *The War Crime of Child Soldier Recruitment*, 2014, ទំព័រ ៨៣។

[៧៦] *សូមមើលគេហទំព័រ* https://rscsl.org/the-scsl/cases/cdf-the-prosecutor-vs-sam-hinga-norman-moinina-fofana-and-allieu-kondewa/

[៧៧] តុលាការសម្រាប់ប្រទសសៀរ៉ាឡេអូន រដ្ឋអាជ្ញា តទល់នឹង សេម ហេនហ្គា ន័រម៉ាន់, SCSL-2004-14-AR72(E), អត្ថបទទី១។

សកម្មភាពនេះជាបទល្មើសនៅឡើយទេ។[៧៨] ជាមួយគ្នានេះដែរ គាត់បានលើកឡើងបន្ថែមថា ចំពោះលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ១៩៩៨វិញក៏មិនគ្រប់គ្រាន់អាចចាត់ទុកថាជា បទល្មើសក្នុងទំនៀមទម្លាប់អន្តរជាតិនៅឡើយទេ។ [៧៩]

ក្នុងបញ្ហានេះ រដ្ឋអាជ្ញាបានបន្ថែមសារណារបស់ខ្លួនដោយអះអាងថា ច្បាប់អន្តរជាតិ គឺខុសគ្នាពីប្រព័ន្ធច្បាប់ជាតិ ពីព្រោះ ច្បាប់អន្តរជាតិមិនមានសភា និងអំណាចសម្រេចអនុម័តច្បាប់សម្រាប់ពិភពលោកឡើយ។[៨០] ដូច្នេះគឺមិនអាចមានលិខិតគតិយុត្តដែលអាចកំណត់ថា អំពើណាខ្លះចាត់ទុកជាបទល្មើស ក្រោមទំនៀមទម្លាប់អន្តរជាតិពីកាលបរិច្ឆេទច្បាស់លាស់ឡើយ។[៨១] ប៉ុន្តែការទទួលខុសត្រូវព្រហ្មទណ្ឌលើការជ្រើសរើសទាហានកុមារ ត្រូវផ្អែកលើកត្តាជាច្រើនរួមផ្សំគ្នា។[៨២] ជាដំបូង ទាក់ទងនឹងគោលការណ៍ គ្មានបទល្មើសព្រហ្មទណ្ឌ បើសិនគ្មានច្បាប់ (*Nullum Crimen Sine Lege*) រដ្ឋអាជ្ញាបានលើកឡើងថា គោលការណ៍នេះ មិនអាចប្រើប្រាស់ក្នុងករណីដែលជនល្មើសដឹងថា អំពើដែលខ្លួនប្រព្រឹត្ត ជាអំពើអាចដាក់ទោសបាន ពោលគឺចាំបាច់ទាល់តែ ជនល្មើសដឹងអំពីការបង្កើតតុលាការកាត់ទោសនាពេលអនាគត ឬដឹងអំពីធាតុផ្សំនៃបទល្មើសឡើយ។[៨៣] រដ្ឋអាជ្ញាបានបន្ថែម ដោយលើកយកការប្រកាសកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៨ របស់ប្រធាននៃក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិស្តីពីការហាមឃាត់ការប្រើប្រាស់ទាហានកុមារ និងដាស់តឿនដល់រដ្ឋជាសមាជិកទាំងអស់ឱ្យគោរពនូវកាតព្វកិច្ច ក្រោមច្បាប់អន្តរជាតិ និងដាស់ទោសជនដែលបានរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។[៨៤] លើសពីនេះ ការទទួលខុសត្រូវព្រហ្មទណ្ឌលើការជ្រើសរើសទាហានកុមារត្រូវបានបង្កើតនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ នៅពេលដែលលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិចូលជាធរមានមកម្ល៉េះ។[៨៥]

ក្រោយការលើកឡើងនេះ ក៏មានសារណាពីអង្គការដែលជាប់ពាក់ព័ន្ធ ដូចជាអង្គការយូនីសេហ្វ ("UNICEF") បានលើកឡើងថា តាំងពីខែវិច្ឆិកា ឆ្នាំ១៩៩៦ ការបញ្ចូល និងប្រើប្រាស់កុមារអាយុក្រោម ១៥ឆ្នាំក្នុង

[៧៨] តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន រដ្ឋអាជ្ញា តទល់នឹង សេម ហេនហ្គា នរ៉ម៉ាន់, SCSL-2004-14-AR72(E), អត្ថបទទី១។

[៧៩] តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន រដ្ឋអាជ្ញា តទល់នឹង សេម ហេនហ្គា នរ៉ម៉ាន់, SCSL-2004-14-AR72(E), អត្ថបទទី១។

[៨០] តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន រដ្ឋអាជ្ញា តទល់នឹង សេម ហេនហ្គា នរ៉ម៉ាន់, SCSL-2004-14-AR72(E), អត្ថបទទី៤។

[៨១] ដូចលេខយោងខាងលើ។

[៨២] ដូចលេខយោងខាងលើ។

[៨៣] ដូចលេខយោងខាងលើ។

[៨៤] ដូចលេខយោងខាងលើ។

[៨៥] ដូចលេខយោងខាងលើ។

ជម្លោះប្រដាប់អាវុធ បានក្លាយជាទំនៀមទម្លាប់អន្តរជាតិ និងត្រូវបានក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិទទួលស្គាល់ ក្នុងអំឡុងពេលដែលតាក់តែងលក្ខន្តិកៈស្តីពីតុលាការប្រទេសសៀរ៉ាឡេអូននេះ ហើយការសន្និដ្ឋាននេះត្រូវបានសមាជិកនៃក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ អនុលោមតាមថាបទល្មើសនេះក្លាយជាទំនៀមទម្លាប់អន្តរជាតិតាំងពីឆ្នាំ១៩៩៦ និងបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិ។[៨៦] លើសពីនេះ ការលើកឡើងរបស់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិត្រូវបានគាំទ្រដោយ ច្បាប់ដែលអនុវត្តដោយបណ្តាប្រទេសលើពិភពលោក សេចក្តីសម្រេចរបស់តុលាការសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និងតុលាការសម្រាប់ប្រទេសរ៉្វាន់ដា ("ICTR") បានទទួលស្គាល់ថា ត្រូវមានការទទួលខុសត្រូវព្រហ្មទណ្ឌប្រសិនបើមានការរំលោភបំពានលើពិធីសារបន្ថែមទី១ និងពិធីសារបន្ថែមទី២ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ព្រមទាំងការប្រកាសនានារបស់បណ្តាប្រទេស បើទោះបីជាទើបតែមានការបញ្ជាក់ច្បាស់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ក៏ដោយ។[៨៧] ម្យ៉ាងទៀតកុមារមានអាយុក្រោម ១៥ឆ្នាំ ជាក្រុមដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវទី៤។[៨៨] ពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវទី៤ទាំងពីរ ក៏បានបន្ថែមលើការការពារ ដោយហាមឃាត់អំពីការបញ្ចូលកុមារ ទៅក្នុងជម្លោះប្រដាប់អាវុធ។[៨៩] ទាំងអស់នេះគឺជាភស្តុតាងដែលអាចបញ្ជាក់ពីការហាមឃាត់ការប្រើប្រាស់ទាហានកុមារ បានក្លាយជាផ្នែកមួយនៃទំនៀមទម្លាប់អន្តរជាតិរួចមកហើយ។[៩០]

ចុងក្រោយតុលាការ បានសម្រេចច្រានចោលការលើកឡើងរបស់ភាគីលោក Sam Hinga Norman (សេម ហេនហ្គា នំរម៉ាន់) ដោយលើកយកមាត្រា ៤ (គ) នៃលក្ខន្តិកៈតុលាការ តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន ថា "តុលាការនេះ មានអំណាចក្នុងការកាត់ក្តីលើជនណាដែលបានប្រព្រឹត្តអំពើរំលោភបំពានធ្ងន់ធ្ងរលើទំនៀមទម្លាប់អន្តរជាតិ ដូចជា ការកេណ្ឌ ឬបញ្ចូលកុមារអាយុក្រោម ១៥ឆ្នាំ ទៅក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធ" [៩១] ដែលមានន័យថា ការកាត់ក្តីលើបទល្មើសនេះគឺ មិនបំពានគោលការណ៍ព្រហ្មទណ្ឌអន្តរជាតិពោលគឺ ការគ្មានបទល្មើសព្រហ្មទណ្ឌបើសិន

[៨៦] ដូចលេខយោងខាងលើ, អត្ថបទទី៧។
[៨៧] ដូចលេខយោងខាងលើ។
[៨៨] ដូចលេខយោងខាងលើ។
[៨៩] ដូចលេខយោងខាងលើ។
[៩០] ដូចលេខយោងខាងលើ។
[៩១] លក្ខន្តិកៈស្តីពីតុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន ឆ្នាំ ២០០០, មាត្រា ៤ (គ).

គ្មានច្បាប់ (*Nullum Crimen Sine Lege*) ឡើយ។[៩២] តុលាការក៏បានរកឃើញថា ការហាមឃាត់ ដែលប្រឆាំងនឹងការប្រើប្រាស់ទាហានកុមារ គឺបានចាត់ទុកថាជាបទល្មើស ក្រោមទំនៀមទម្លាប់អន្តរជាតិតាំងពីមុនខែវិច្ឆិកា ឆ្នាំ១៩៩៦មកម្ល៉េះ ដោយតុលាការបានលើកឡើងពីសេចក្ដីសម្រេចរបស់តុលាការ Nuremberg ថា "ច្បាប់សង្គ្រាមគឺមិនពឹងផ្អែកតែលើតែសន្ធិសញ្ញាឡើយ ប៉ុន្តែក៏ផ្អែកលើទំនៀមទម្លាប់ និងការអនុវត្តរបស់ប្រទេសនានាជាបន្តបន្ទាប់ ដែលទទួលបានការទទួលស្គាល់ ព្រមទាំងពឹងផ្អែកលើគោលការណ៍ទូទៅនៃយុត្តិធម៌ ដែលប្រើប្រាស់ដោយអ្នកច្បាប់ និងការអនុវត្តរបស់តុលាការយោធា។[៩៣] ច្បាប់ទាំងនេះមិនអាចនៅស្ថិតស្ថេរបានទេ ពោលគឺត្រូវប្រែប្រួលទៅតាមតម្រូវការនៃបម្រែបម្រួលរបស់ពិភពលោក។[៩៤] ជាការពិត ក្នុងករណីជាច្រើនបានបង្ហាញថា សន្ធិសញ្ញា មិនបានបញ្ជាក់អ្វីឡើយ ក្រៅពីការបង្ហាញ និងកំណត់អត្ថន័យត្រឹមត្រូវបន្ថែមទៀតលើគោលការណ៍នៃច្បាប់ដែលមានស្រាប់។" [៩៥]

ប៉ុន្តែជាអកុសលនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ លោក Sam Hinga Norman (សេម ហេនហ្គា ន័រម៉ាន់) បានស្លាប់ មុននឹងការចេញសាលក្រមពីតុលាការ ដែលធ្វើឱ្យអង្គជំនុំជំរះសម្រេចបញ្ឈប់នីតិវិធីនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៧។[៩៦] ទោះជាយ៉ាងណា សេចក្ដីសម្រេចរបស់តុលាការនេះ បានបង្ហាញពីទំនៀមទម្លាប់អន្តរជាតិ លើការហាមឃាត់ការប្រើប្រាស់ និងបញ្ចូលកុមារទៅក្នុងជម្លោះប្រដាប់អាវុធ និងក្លាយជាការចង្អុលបង្ហាញមួយសម្រាប់តុលាការអន្តរជាតិ តុលាការក្នុងស្រុក និង តុលាការកូនកាត់ នាពេលអនាគតដើម្បីដោះស្រាយអំពីបញ្ហានេះ។

ក្រោយមកតុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន បានកាត់ទោស បានសម្រេចជាលើកដំបូងលើករណីការប្រើប្រាស់ទាហានកុមារ ក្នុងសំណុំរឿងលោក Alex Tamba ('Gullit') Brima, Ibrahim ('Bazzy') Kamara and Santigie Borbor ('Five–Five') Kanu ដែលជា សមាជិករបស់ក្រុមឧទ្ទាម Armed Forces Revolutionary Council ("The AFRC")។[៩៧] ព្រះរាជអាជ្ញាបានចោទប្រកាន់ លោក Brima, លោកKamara និងលោក Kanu ពីបទការកេណ្ឌ បញ្ចូល និងប្រើប្រាស់ទាហានកុមារក្នុងកម្លាំងប្រដាប់អាវុធ ដែលមានអាយុក្រោម ១៥ឆ្នាំ ចំនួនរាប់ពាន់នាក់ ទៅតាមជំរុំរបស់AFRC ដើម្បីយកពួកគេមកហ្វឹកហាត់ទាហាន បែងចែកទៅតាម

---

[៩២] តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន រដ្ឋអាជ្ញា តទល់នឹង សេម ហេនហ្គា ន័រម៉ាន់, SCSL-2004-14-AR72(E), អត្ថបទទី៤៥។

[៩៣] តុលាការយោធាអន្តរជាតិ Nuremburg, សេចក្ដីសម្រេចចុះថ្ងៃទី ១ ខែតុលាការ១៩៤៦, ទំព័រទី ៥៤។

[៩៤] ដូចលេខយោងខាងលើ។

[៩៥] ដូចលេខយោងខាងលើ។

[៩៦] *សូមមើល* https://rscsl.org/the-scsl/cases/cdf-the-prosecutor-vs-sam-hinga-norman-moinina-fofana-and-allieu-kondewa/

[៩៧] *សូមមើល* Juline McBride, *The War Crime of Child Soldier Recruitment*, ទំព័រទី ១១១។

ក្រុមវង់ ក្រុមកុមារា និងក្រុមកុមារី ដើម្បីប្រើប្រាស់ពួកគេចូលទៅប្រយុទ្ធក្នុងជម្លោះប្រដាប់អាវុធ។[៩៨] តុលាការបានរកឃើញភស្តុតាងគ្រប់គ្រាន់ អំពីការកេណ្ឌ ការបញ្ចូល និងប្រើប្រាស់កុមារអាយុ ១៥ឆ្នាំក្នុងជម្លោះប្រដាប់អាវុធ ដោយក្រុម AFRC ប្រើប្រាស់កុមារ ព្រោះពួកគេគិតថាកុមារទាំងនោះ ងាយស្រួលក្នុងការបោកបញ្ឆោត និងប្រើប្រាស់មនោគមន៍ឱ្យចូលក្នុងសមរភូមិ។[៩៩] តុលាការបានសម្រេចដាក់ទោសលោក Brima ឱ្យជាប់ពន្ធនាគារចំនួន ៥០ឆ្នាំ លោកKamara ចំនួន ៤៥ឆ្នាំ និងលោកKanu ចំនួន ៥០ឆ្នាំ។[១០០]

### ៣.១.២. សាលក្រមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

ចំណែកឯ ក្នុងលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ១៩៩៨ វិញ បានចែងអំពីបទឧក្រិដ្ឋកម្មសង្គ្រាមការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធ ក្នុងមាត្រា ៨ (២) (ខ) (២៦) ករណីដែលប្រព្រឹត្តក្នុងជម្លោះប្រដាប់អាវុធមានលក្ខណៈអន្តរជាតិ និងមាត្រា ៨ (២) (ង) (៧) ករណីដែលប្រព្រឹត្តិក្នុងជម្លោះប្រដាប់អាវុធ ដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ។ ការកំណត់និយមន័យរបស់ ពាក្យ "**កេណ្ឌ**" គឺមានន័យថា ការបង្ខំឱ្យទទួលកាតព្វកិច្ចក្នុងការចូលជាទាហាន ឬតាមវិធីចាប់ជំរិត ឬពង្រត់ក្មេង (*abduction*) និងពាក្យ "**បញ្ចូល**" មាននន័យថាចុះឈ្មោះនៅក្នុងបញ្ជីនៃជួរទាហាន ("*to enroll on the list of a military body*") ។[១០១] ក្នុងន័យនេះ "**ការកេណ្ឌ**" និងពាក្យ "**ការបញ្ចូល**" គឺមានអត្ថន័យដូចគ្នាគ្រាន់តែពាក្យ "**ការកេណ្ឌ**" អាចផ្តល់ឆន្ទានុសិទ្ធិឱ្យតុលាការអាចបកស្រាយទៅតាមករណីនីមួយៗ ដោយមើលលើកម្រិតនៃការប្រើប្រាស់កម្លាំង ការគម្រាមកំហែងតាមផ្លូវកាយ និងការដាក់សម្ពាធដែលធ្វើឱ្យកុមារទាំងនោះចូលក្នុងកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះ។[១០២] ធាតុផ្សំនៃច្បាប់នៃការកេណ្ឌ និងបញ្ចូលនេះអាចរកឃើញក្នុងករណីដែលកុមារចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ដោយសារហេតុផលដូចជា កាតព្វកិច្ចច្បាប់ ការចាប់

---

[៩៨] តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន រដ្ឋអាជ្ញា តទល់នឹង ប្រាម៉ា, ខាម៉ារ៉ា និងខានូ, SCSL-16-56 ( 21 April 2004 ), អត្ថបទទី ១២៤៤។

[៩៩] *សូមមើល* Juline McBride, *The War Crime of Child Soldier Recruitment*, ទំព័រទី ១១៤។

[១០០] *សូមមើល* Juline McBride, *The War Crime of Child Soldier Recruitment*, ទំព័រទី ១១៤។

[១០១] *សូម*មើល ការិយាល័យរដ្ឋអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិស្តីពី គោលការណ៍លើកុមារ, https://www.icc-cpi.int/sites/default/files/iccdocs/otp/20161, អត្ថបទទី៤១។

[១០២] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង អុងវេន, ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១, រឿងក្តីលេខ ICC-02/04-01/15, ២០២១, អត្ថបទទី ២៧៦៩។

បង្ខំរូបរាងកាយ ការគម្រាមគំហែងប្រើប្រាស់កម្លាំង ឬការដាក់សម្ពាធផ្នែកផ្លូវអារម្មណ៍ដោយបញ្ចុះបញ្ចូល និងញុះញង់។[១០៣]

ជាក់ស្តែង នៅអំឡុងឆ្នាំ២០០២ តុលាការព្រហ្មទណ្ឌអន្តរជាតិបានដំណើរការ យើងឃើញថា ការកាត់ទោសទៅលើបទឧក្រិដ្ឋកម្មសង្គ្រាមការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងការជម្លោះប្រដាប់អាវុធ មានចំនួន ៣ ករណីប៉ុណ្ណោះ។

ករណីដំបូងគឺក្នុងសេចក្តីសម្រេចកាត់ទោសលោក Thomas Lubanga Dyilo ("លូងបាងហ្គា") ជាអគ្គមេបញ្ជាការក្រុមឧទ្ទាម Patriotiques pour la Libération du Congo ("FPLC")។[១០៤] នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋអាជ្ញា បានចោទប្រកាន់ Thomas Lubanga Dyilo ("លូងបាងហ្គា") អំពីបទឧក្រិដ្ឋកម្មសង្គ្រាម ការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងការជម្លោះប្រដាប់អាវុធ តាមមាត្រា ៨ (២) (ង) (៧) នៃលក្ខន្តិកៈរ៉ូម ដោយគិតចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដែលបទល្មើសនេះប្រព្រឹត្តឡើងក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ។[១០៥]

ការប្រើប្រាស់កុមារមានដូចជា ការយកកុមារមកហ្វឹកហាត់ ដើម្បីចូលរួមក្នុងសមរភូមិ ហើយអគ្គមេបញ្ជាការ FPLC ក៏បានបញ្ចូលកុមារដែលមានអាយុក្រោម ១៥ឆ្នាំទាំងនោះទៅក្នុងជួរមុខដើម្បីប្រយុទ្ធ ជាពិសេស តំបន់ Libi និង Mbau ក្នុងខែតុលា ឆ្នាំ២០០២, នៅតំបន់ Largu ក្នុងដើមឆ្នាំ២០០៣, នៅតំបន់ Lipri និង Bogoro ក្នុងខែកុម្ភៈ និងមីនា ឆ្នាំ២០០៣, នៅតំបន់ Bunia ក្នុងខែមេសា ឆ្នាំ២០០៣។[១០៦] ក្នុងការប្រយុទ្ធនោះ កុមារដែលមានអាយុក្រោម ១៥ឆ្នាំ ត្រូវប្រើប្រាស់អាវុធ និងត្រូវបានគេបញ្ជាឱ្យធ្វើការសម្លាប់ រីឯកុមារខ្លះទៀតត្រូវបានបាត់បង់ជីវិតក្នុងសមរភូមិនោះ។[១០៧] តុលាការក៏បានរកឃើញថា Thomas Lubanga Dyilo ("លូងបាងហ្គា") បានប្រើប្រាស់កុមារអាយុក្រោម ១៥ឆ្នាំ ធ្វើជាអង្គរក្សផ្ទាល់របស់ខ្លួន ព្រមទាំងធ្វើជាកងឈ្លប

---

[១០៣] *សូម*មើល ការិយាល័យរដ្ឋអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិស្តីពី គោលការណ៍លើកុមារ, https://www.icc-cpi.int/sites/default/files/iccdocs/otp/20161, អត្ថបទទី២០។

[១០៤] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង ថូម៉ាស លូបាងហ្គា, 29 មករា ២០០៧, រឿងក្តីលេខ ICC-01/04-01/06, អត្ថបទទី៨។

[១០៥] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង ថូម៉ាស លូបាងហ្គា, 29 មករា ២០០៧, រឿងក្តីលេខ ICC-01/04-01/06, អត្ថបទទី៩។

[១០៦] ដូចលេខយោងខាងលើ, អត្ថបទទី២៦៦។

[១០៧] ដូចលេខយោងខាងលើ, អត្ថបទទី២៦៦។

ក្នុងពេលពង្រាយទ័ព ដែលអាចមានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់កុមារទាំងនោះ។[១០៨] លើសពីនេះកុមារអាយុក្រោម ១៥ឆ្នាំក៏ទទួលខុសត្រូវផងដែរ ក្នុងការការពារទីស្នាក់ការកណ្តាល និងបុគ្គលិកទូទៅរបស់ក្រុមឧទ្ទាមនេះ ដែលមានទីតាំងនៅ Bunia។ [១០៩]

ក្រោយពីបានពិនិត្យមើលលើភស្តុតាង អង្គហេតុ និងអង្គច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានសម្រេចដាក់ទោសលោក Thomas Lubanga Dyilo ("លូងបាងហ្គា") ជាប់ពន្ធនាគារចំនួន ១៤ឆ្នាំ ពីបទឧក្រិដ្ឋកម្មសង្គ្រាម ការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធ មាត្រា ៨ (២) (ង) (៧) នៃ លក្ខន្តិកៈរ៉ូម។[១១០] នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៥ Thomas Lubanga Dyilo ("លូងបាងហ្គា") ត្រូវបានបញ្ជូលទៅពន្ធនាគារនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ ជាចុងក្រោយ គាត់ត្រូវបានដោះលែងនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ បន្ទាប់ពីបានជាប់ពន្ធនាគារតាមការសម្រេចរបស់តុលាការ។[១១១]

ចំណែកឯសេចក្តីសម្រេចទី២ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានកាត់ទោសលើលោក Bosco Ntaganda ("ណាហ្គានដា") ជាអតីតមេបញ្ជាការក្រុមឧទ្ទាម Forces Patriotiques Pour La Libération Du Congo ("FPLC") ដែលបានជ្រើសរើសកុមារដោយមិនគិតពីអាយុនៅក្នុងតំបន់ជាច្រើននៃសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ (Democratic Republic of the Congo) ហៅកាត់ថា ("DRC") ដូចជា នៅ Ituri, Bunia និងតំបន់ជនបទ តាំងពីខែមិថុនា ឆ្នាំ២០០២។[១១២] ការចាប់ផ្តើមជ្រើសរើសនេះគឺ សមាជិករបស់ក្រុមឧទ្ទាម UPC និង FPLC បានបញ្ចុះបញ្ចូលមនុស្សចាស់ ក៏ដូចជាប្រធានសហគមន៍ ពិសេសនៅ Ituri ដោយឱ្យជ្រើសរើសកុមារ និងយុវជនចូលមកក្នុងក្រុមរបស់ពួកគេ។[១១៣] ក្រុមឧទ្ទាមទាំងនោះ បានប្រាប់ទៅ ប្រធានសហគមន៍ និងឪពុកម្តាយគ្រប់រូបថា ក្រុមខ្លួនត្រូវការកម្លាំងក្មេងៗដើម្បីការពារសហគមន៍របស់ពួកគេ ប្រឆាំងនឹងពួក Lendu។[១១៤]

---

[១០៨] ដូចលេខយោងខាងលើ, អត្ថបទទី២៦៧។

[១០៩] ដូចលេខយោងខាងលើ, អត្ថបទទី២៦៧។

[១១០] ដូចលេខយោងខាងលើ, អត្ថបទទី៩៩។

[១១១] *សូមមើល* តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង ថូម៉ាស លូបាងហ្គា, *រកបានលើគេហទំព័រ* https://www.icc-cpi.int/drc/lubanga

[102] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង ណាហ្គានដា, ០៨ កក្កដា ២០១៩, រឿងក្តីលេខ ICC-01/04-02/06, អត្ថបទទី ១១១៧។

[១១៣] ដូចលេខយោងខាងលើ។

[១១៤] ដូចលេខយោងខាងលើ។

ក្រោយមកក្រុមឧទ្ទាម UPC និង FPLC បានដាក់ជាកាតព្វកិច្ច និងគម្រាមឱ្យរាល់គ្រួសារ ត្រូវតែបញ្ជូនកូនម្នាក់ ឬច្រើននាក់មកក្នុងក្រុមរបស់ពួកគេ។[១១៥] គ្រួសារខ្លះត្រូវបង់ប្រាក់មួយចំនួន ដើម្បីជាថ្នូរមិនបញ្ជូនកូនៗរបស់ពួកគេឱ្យចូលក្នុងក្រុមឧទ្ទាមនេះ។[១១៦] ជាមួយគ្នានេះដែរ តុលាការបានកំណត់ថា យ៉ាងហោចណាស់ ចាប់ពីខែឧសភា ឆ្នាំ២០០៣ ដល់ខែកុម្ភៈ ឆ្នាំ២០០៣ កុមារក្រោមអាយុ ១៥ឆ្នាំត្រូវបានបង្ខំឱ្យចូលរឹកហាត់មូលដ្ឋានជាទាហាននៅជំរឹកហាត់ជាច្រើនរបស់ក្រុម UPC និងFPLC។[១១៧] ការរឹកហាត់មូលដ្ឋានទាំងនោះរួមមានការបង្រៀនឱ្យប្រើប្រាស់អាវុធ ការដើរក្បួនព្យុហយាត្រា ការប្រមៀលខ្លួន ការគោរពបែបទាហាន និងច្បាប់ទម្លាប់ទាហានផងដែរ។[១១៨] ការរឹកហាត់នេះគឺ មើលទៅលើតែសមត្ថភាព និងសុខភាពផ្លូវកាយប៉ុណ្ណោះ ដោយមិនគិតពីអាយុឡើយ ដែលជាក់ស្តែងនៅ ជំរុំ Lingo មានទាំងក្មេងស្រីដែលមានអាយុប្រហែល ៩ឆ្នាំ ចូលរឹកហាត់ទាហាន។[១១៩] កុមារខ្លះត្រូវបានឱ្យរឹកហាត់ប្រើប្រាស់ការបាញ់រ៉ុក្កែត(rocket) និងយ៉ាងហោចណាស់កុមារមានអាយុក្រោម ១៥ឆ្នាំចំនួន ២នាក់ ត្រូវបានបង្វឹកឱ្យក្លាយជាប្រតិបត្តិករវិទ្យុ (radio operators) ស្ថិតក្នុងទីលំនៅរបស់លោក Bosco Ntaganda ("ណាហ្គានដា")។[១២០] សម្រាប់ក្មេងៗដែលនៅតាមជំរុំ ត្រូវបានក្រុមឧទ្ទាមនេះគម្រាមសម្លាប់ប្រសិនបើពួកគេព្យាយាមរត់ចេញពីជំរុំ។[១២១] ជាក់ស្តែងនៅជំរុំ Mandro អ្នកដែលបានព្យាយាមរត់គេច ត្រូវបានវាយជាដំណំ និងត្រូវបានដាក់ក្នុងគុកក្រោមដី មួយរយៈផងដែរ។[១២២] ពេលខ្លះ ពួកគេត្រូវបានប្រើប្រាស់ឱ្យចូលរួមក្នុងសមរភូមិ ដោយមិនគិតពីអាយុ ហើយកុមារដែលមានអាយុក្រោម ១៥ឆ្នាំជាច្រើនត្រូវបានប្រើប្រាស់ក្នុងផ្នែកជាច្រើនរបស់ក្រុមUPC និង FPLC។[១២៣] លើសពីនេះ លោក Bosco Ntaganda ("ណាហ្គានដា") និងសមាជិករបស់ខ្លួន បានយកកុមារមានអាយុក្រោម ១៥ឆ្នាំ មកធ្វើជាកងកម្លាំងការពារផ្ទាល់រាល់ពេលខ្លួនធ្វើដំណើរចេញក្រៅទៅសង្កេតការណ៍តាមជំរុំ រួមទាំងនៅពេលដែលខ្លួនត្រូវចេញទៅជួបប្រជុំមេបញ្ជាការផ្សេងៗដូចជាលោក Thomas Lubanga, Rafiki, និង Floribert Kisembo និងយកកុមារទាំងនោះធ្វើជាកងកម្លាំងការពារទីលំនៅ

[១១៥] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង ណាហ្គានដា, ០៨ កក្កដា ២០១៩, រឿងក្តីលេខ ICC-01/04-02/06, អត្ថបទទី១១១៨។
[១១៦] ដូចលេខយោងខាងលើ។
[១១៧] ដូចលេខយោងខាងលើ, អត្ថបទទី ១១២០។
[១១៨] ដូចលេខយោងខាងលើ។
[១១៩] ដូចលេខយោងខាងលើ។
[១២០] ដូចលេខយោងខាងលើ។
[121] ដូចលេខយោងខាងលើ។
[១២២] ដូចលេខយោងខាងលើ។
[១២៣] ដូចលេខយោងខាងលើ, អត្ថបទទី ១១២១។

របស់ខ្លួន។[១២៤] កុមារទាំងនោះ ត្រូវបានក្រុម UPC និង FPLC ប្រើប្រាស់ឱ្យធ្វើជាអ្នកសើបការណ៍ អ្នកដើរល្បាត និងចាប់ចោរដែលចូលមកក្នុងជំរុំរបស់ពួកគេ។[១២៥] តុលាការបានពិនិត្យឃើញថា តាមរយៈភស្តុតាង និងសាក្សីដែលបានបង្ហាញអំពីការចូលប្រយុទ្ធក្នុងជម្លោះប្រដាប់អាវុធ ព្រមទាំងការពារមេបញ្ជាការ អគ្គមេបញ្ជាការក្រុម UPC និង FPLC ដោយកុមារមានអាយុក្រោម ១៥ឆ្នាំ ពិតជាបញ្ជាក់អំពីការចូលរួមយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធ អំឡុងពេលដែលមានជម្លោះប្រដាប់អាវុធ ដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ នៅតំបន់ Ituri ហើយកុមារទាំងនោះក្លាយជាគោលដៅដែលអាចវាយប្រហារស្របច្បាប់បាន (legitimate military targets)។[១២៦] តុលាការបានសម្រេចដាក់ទោសលោក Ntaganda ពីបទឧក្រិដ្ឋកម្មសង្គ្រាម ការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធចាប់ពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០០២ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៣ និង ប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធ ពីថ្ងៃទី៦ ខែសីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៣ មាត្រា ៨ (២)(ង)(៧) នៃ លក្ខន្តិកៈរ៉ូម ត្រូវជាប់ពន្ធនាគារចំនួន ១៨ ឆ្នាំ ហើយ ផ្តន្ទាទោសសរុបជាមួយបទល្មើសផ្សេងទៀត សរុបចំនួន ៣០ឆ្នាំ។ [១២៧]

លើសពីនេះ ក្នុងសេចក្តីសម្រេចឆ្នាំ ២០២១ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានកាត់ក្តីលើលោក Dominic Ongwen ("អុងវេន") ជាមេបញ្ជាការរបស់ក្រុម Sinia Bridge ("កងពលតូច ស៊ីណា") របស់ក្រុមឧទ្ទាម Lord's Resistance Army ("LRA") ដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម ការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធ មាត្រា ៨ (២)(ង)(vii) នៃ លក្ខន្តិកៈរ៉ូម។ [១២៨]

ការប្រព្រឹត្តបទល្មើសនេះ Dominic Ongwen ("អុងវេន") បានពឹងលើក្រុមទាហាន LRA ដែលនៅក្រោមការដឹកនាំរបស់ខ្លួន ឱ្យចាប់បង្ខំកុមារក្រោម១៥ឆ្នាំ នៅភាគខាងជើងនៃប្រទេសអ៊ូហ្គាន់ដា ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥។[១២៩] កុមារទាំងនោះត្រូវបានបង្ខំអោយចូលរឹកហាត់ទាហាន ពេលខ្លះ

---

[១២៤] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង ណាហ្គានដា, ០៨ កក្កដា ២០១៩, រឿងក្តីលេខ ICC-01/04-02/06, អត្ថបទទី១១២៦។
[១២៥] ដូចលេខយោងខាងលើ, អត្ថបទទី ១១២៧។
[១២៦] ដូចលេខយោងខាងលើ, អត្ថបទទី ១១២៨។
[១២៧] ដូចលេខយោងខាងលើ, ទំព័រទី ៥៣៨។
[១២៨] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង អុងវេន, ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១, រឿងក្តីលេខ ICC-02/04-01/15, ២០២១, អត្ថបទទី ១៣៤ និង ៣១១៥។
[១២៩] ដូចលេខយោងខាងលើ, អត្ថបទទី ២២៣។

ត្រូវបានអោយកាន់អាវុធ។ លោក Domanic Ongwen ផ្ទាល់ក៏បានចូលរួមដោយផ្ទាល់ ក្នុងការចាប់បង្ខំឱ្យក្មេងស្រីក្រោមអាយុ ១៥ឆ្នាំ មកបម្រើសេវាកម្មផ្លូវភេទ សម្រាប់ក្រុមឧទ្ទាម និងនៅក្នុងផ្ទះរបស់ខ្លួនផ្ទាល់។[១៣០]

មិនតែប៉ុណ្ណោះ កុមារអាយុក្រោម ១៥ឆ្នាំ ត្រូវបានបង្ខំឱ្យចូលជាទាហាន Sinia brigade (កងពលតូច Sinia) និងចូលប្រយុទ្ធក្នុងសមរភូមិ។ ពួកគេត្រូវបានបញ្ជូនឱ្យធ្វើជាកងជំនួយ នៅពេលដែល ក្រុមទាហានLRA ចូលវាយប្រហារនានា ដោយធ្វើជាអ្នកផ្តល់ដំណឹង, ដុតកម្ទេច, ចូលប្លន់ផ្ទះប្រជាជន, ចូលប្រមូលវត្ថុដែលបានមកពីការវាយប្រហារប្រជាជន និងជាអ្នកសើបការណ៍។[១៣១]

ដោយផ្អែកលើភស្តុតាងខាងលើ ដែលលោក Dominic Ongwen ("អុងវេន") បានចាប់បង្ខំកុមារក្រោមអាយុ ១៥ឆ្នាំ តាមរយៈទាហានក្រោមឱវាទ ការប្រព្រឹត្តដោយខ្លួនលោកផ្ទាល់ និងជាអ្នករៀបគម្រោងការណ៍ដោយផ្ទាល់ផងនោះ លោក Dominic Ongwen ("អុងវេន") ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម ការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបំពេការយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធ មាត្រា ៨ (២)(ង)(៧) នៃ លក្ខន្តិកៈទីក្រុងរ៉ូមដោយកាន់ទោសឱ្យជាប់ពន្ធនាគារចំនួន ២០ឆ្នាំ និងសរុបចំនួន២៥ឆ្នាំ រួមនឹងបទចោទផ្សេងៗទៀត។[១៣២] ប៉ុន្តែភាគីលោក Dominic Ongwen ("អុងវេន") បានបន្តប្តឹងទៅសភាឧទ្ធរណ៍ ដោយលើកមូលហេតុនៃស្ថានសម្រាលទោសថា Dominic Ongwen ("អុងវេន") ជាអតីតទាហានកុមារមុននឹងការប្រព្រឹត្តបទល្មើស ជាផ្អែកមួយជំរុញឱ្យលោកប្រព្រឹត្តបទល្មើសទាំងនេះ។[១៣៣] ទោះជាយ៉ាងណាក៏ សភាឧទ្ធរណ៍នៅតែច្រានចោលការលើកឡើងរបស់ភាគី Dominic Ongwen ("អុងវេន") ដោយសារការលើកឡើងនេះមិនបានបំពេញគ្រប់លក្ខខណ្ឌក្នុងមាត្រា៣១ នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិនោះឡើយ។[១៣៤] យ៉ាងណាមិញ សភាឧទ្ធរណ៍ បានសម្រេចតម្កល់ទុកសេចក្តីសម្រេចរបស់សភាអង្គជំនុំជំរះ ដោយឱ្យលោក Dominic Ongwen ("អុងវេន") ជាប់ពន្ធនាគារចំនួន ២៥ឆ្នាំ។[១៣៥]

---

[១៣០] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង អុងវេន, ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១, រឿងក្តីលេខ ICC-02/04-01/15, ២០២១, អត្ថបទទី ២២៤។

[១៣១] ដូចលេខយោងខាងលើ, អត្ថបទទី ២២៥។

[១៣២] ដូចលេខយោងខាងលើ, អត្ថបទទី ១៣៨។

[១៣៣] *សូមមើល* តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹងអុងវេន, *រកបានលើគេហទំព័រ* https://www.icc-cpi.int/news/ongwen-case-icc-appeals-chamber-confirms-conviction-and-sentencing-decisions

[១៣៤] ដូចលេខយោងខាងលើ។

[១៣៥] ដូចលេខយោងខាងលើ។

ដូចគ្នានេះដែរ យើងឃើញថា បើទោះបីនៅតុលាការ Ad Hoc ដែលបានបង្កើតឡើងកន្លងមកមានករណីខ្លះ ដែលពុំបានសម្រេចដាក់ទោសជនល្មើសដែលបានប្រើប្រាស់កុមារនៅក្នុងកងកម្លាំងប្រដាប់អាវុធ ឬក្នុងជម្លោះប្រដាប់អាវុធឡើយ ប៉ុន្តែសេចក្តីសម្រេចខ្លះក៏បានក្លាយជំនួយក្នុងការបកស្រាយច្បាប់ សម្រាប់តុលាការក្រោយៗ។ លើសពីនេះទៀត យើងឃើញមានសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិលើជនដែលបានកេណ្ឌ និងបញ្ចូលទាហានកុមារក្នុងជម្លោះប្រដាប់អាវុធ។ យ៉ាងណាមិញ សេចក្តីសម្រេចរបស់តុលាការគឺមិនទាន់ឆ្លើយតបទៅនឹងចំនួននៃការប្រើប្រាស់ទាហានកុមារនៅឡើយទេពីព្រោះយើងឃើញថា ការប្រើប្រាស់កម្លាំងកុមារនៅដែលមានក្នុងការអនុវត្តផ្ទាល់ ដោយហេតុថា នៅមានកង្វះខាតនៃច្បាប់អន្តរជាតិ។

## ៣.២. ចំណុចខ្វះចន្លោះនៃច្បាប់អន្តរជាតិចំពោះការបញ្ឈប់ការប្រើប្រាស់ទាហានកុមារ

ដោយគិតត្រឹមបច្ចុប្បន្ននេះ បណ្តាប្រទេសនានា និងអន្តរជាតិបានបង្កើតច្បាប់ ដើម្បីគាំពារកុមារពីការកេណ្ឌ និងជ្រើសរើសឱ្យចូលជាទាហានកុមារដែលច្បាប់ធំៗទាំងនោះរួមមាន ពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៧៧ អនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារជំរើសតាមចិត្ត ចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធត្រូវបានអនុវត្តព្រមទាំងច្បាប់ ដែលដាក់ទណ្ឌកម្មចំពោះបុគ្គល ដែលត្រូវទទួលខុសត្រូវ លើការប្រព្រឹត្តបទល្មើសនេះដូចជាលក្ខន្តិកៈទីក្រុងរ៉ូម លក្ខន្តិកៈតុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន ដែលបានផ្តន្ទាទោសលើការបំពានច្បាប់ដែលពាក់ព័ន្ធ។[១៣៦]

បើទោះបីជាច្បាប់អន្តរជាតិត្រូវបានបង្កើតឡើង រួមនឹងសេចក្តីសម្រេចដាក់ទោសលើមេដឹកនាំ ដែលបានកេណ្ឌ និងជ្រើសរើសទាហានកុមារឱ្យចូលរួមយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធក៏ដោយ ប៉ុន្តែនៅក្នុងការអនុវត្ត ការប្រើប្រាស់ទាហានកុមារនៅតែមាន និងកើនឡើងជាលំដាប់។[១៣៧] ជាក់ស្តែង គិតចាប់ពីឆ្នាំ២០០៥ ដល់ ឆ្នាំ២០២២ មានកុមារច្រើនជាង ១០៥,០០០នាក់ ដែលត្រូវបានភាគីនៃជម្លោះប្រដាប់អាវុធ កេណ្ឌ និងបញ្ចូល ឱ្យធ្វើជាទាហាន។[១៣៨] ទាហានកុមារទាំងនោះ រួមមានក្មេងប្រុស និងក្មេងស្រី ដែលត្រូវរងការរំលោភបំពាន ដោយបង្ខំឱ្យចូលក្នុងការប្រយុទ្ធ ព្រមទាំងជាអ្នកស៊ើបការណ៍ អ្នកការពារ ឆ្មាំ អ្នកបញ្ជូនសារ ចុងភៅ និងក្នុងទម្រង់ផ្សេងៗ ពិសេសក្មេងស្រីដែលជាកម្មវត្ថុនៃការរំលោភបំពានខ្លាំង។ [១៣៩]

---

[១៣៦] *សូមមើល* Sarah J. Diaz, *An exclusive Mandate: Enforcing the Prohibition on the Use of Child Soldiers*, ឆ្នាំ ២០១៩, ទំព័រទី ១១។

[១៣៧] *សូមមើល* អង្គការយូនីសេហ្វ ការបញ្ចូលកុមារក្នុងកងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ, *រកបានលើគេហទំព័រ* https://www.unicef.org/protection/children-recruited-by-armed-forces

[138] ដូចលេខយោងខាងលើ។

[១៣៩] ដូចលេខយោងខាងលើ។

ជាក់ស្តែងយើងឃើញមានបញ្ហាប្រឈមមួយចំនួន ដែលធ្វើឱ្យការកាត់ទោសទាក់ទងនឹងបទល្មើសប្រើប្រាស់ទាហានកុមារនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនេះពុំអាចធ្វើទៅបាន។[១៤០] បញ្ហាប្រឈមទាំងនោះមានបញ្ហាប្រឈមទាក់ទងនឹងរចនាសម្ព័ន្ធនៃច្បាប់ ដូចជាការផ្តល់ឆន្ទានុសិទ្ធិ ការកំណត់អតិបរមាអាយុកុមារក្នុងបទល្មើសរបស់ច្បាប់ និងបញ្ហាប្រឈមទាក់ទងនឹងការអនុវត្ត។[១៤១]

បញ្ហាប្រឈមទីមួយដែលទាក់ទងនឹងរចនាសម្ព័ន្ធនៃច្បាប់អន្តរជាតិនោះគឺ ការផ្តល់ឆន្ទានុសិទ្ធិដល់ចៅក្រមក្នុងការកំណត់ថាតើសកម្មភាពណាខ្លះ ត្រូវបានចាត់ទុកថាជា សកម្មភាពកុមារដែលជាប់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ដែលជាធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម។[១៤២] ជាក់ស្តែង សេចក្តីសម្រេចរបស់ សភាឧទ្ធរណ៍ក្នុងតុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន លើលោក Monina Fofana (ម៉ូនីណា ហ្វូហ្វាណា) និងលោក Allieu Kondewa (អាលីវ កូនឌីវ៉ា) បានសម្រេច លើកចោលការចោទប្រកាន់លើលោក Monina Fofana (ម៉ូនីណា ហ្វូហ្វាណា) ពីបទបញ្ចូលកុមារជាទាហាន ដោយសារការបកស្រាយនៃពាក្យ "បញ្ចូល" កុមារទៅក្នុងកម្លាំងប្រដាប់អាវុធ និងក្រោមហេតុផលថាមិនមានយុត្តិសាស្ត្រគ្រប់គ្រាន់ក្នុងការបកស្រាយពាក្យគន្លឹះខាងលើ។[១៤៣]

បញ្ហានេះគឺកើតឡើងមកពីមានវិមតិសង្ស័យលើសាក្សីមួយរូប ដោយតុលាការចោទសួរថា តើការ "បញ្ចូល" កុមារជាទាហានអាចធ្វើឡើងបានតែមួយដង ឬវាអាចកើតឡើងតាមរយៈសកម្មភាពច្រើន ហើយថាតើកុមារម្នាក់អាចត្រូវបានគេ "បញ្ចូល"ជាទាហានកុមារលើសពីមួយដងដែរឬទេ?។[១៤៤] សភាឧទ្ធរណ៍បានសម្រេចបកស្រាយបញ្ហានេះ ដោយលើកឡើងថា ពាក្យ "បញ្ចូល" ទាហានកុមារនេះ ត្រូវបានពិចារណាលើ ២ធាតុផ្សំ។ ក្នុងនោះធាតុផ្សំទីមួយ គឺ "បញ្ចូល" ត្រូវរាប់ទាំង ពេលដែលពួកក្រុមឧទ្ទាមប្រើប្រាស់ឱ្យលើកគ្រឿងសព្វាវុធ ពីព្រោះសកម្មភាពនេះក៏ភ្ជាប់ជាមួយជម្លោះប្រដាប់អាវុធផងដែរ។ រីឯធាតុផ្សំទីពីរ គឺសំដៅលើធាតុអត្តនោម័ត ដែលសំដៅលើជនល្មើសថា តើខ្លួនបានដឹងថាកុមារទាំងនោះមានអាយុក្រោម១៥ឆ្នាំឬទេ។[១៤៥] តុលាការបានសម្រេចមិនប្រើប្រាស់ *dolus directus* កម្រិតទី២ នៃធាតុអន្តោម័ត គឺស្ថានភាពដែលជនល្មើសបាន

---

[១៤០] *សូមមើល* Sandhya Nair, *Child Soldiers And International Criminal Law: Is The Existing Legal Framework Adequate To Prohibit The Use Of Children In Conflict ?*, ឆ្នាំ ២០១៧, ទំព័រទី ៥៣

[១៤១] ដូចលេខយោងខាងលើ។

[១៤២] *សូមមើល* Julie McBride, *The War Crime of Child Soldier Recruitment*, ឆ្នាំ ២០១៤, ទំព័រទី ១៤២

[១៤៣] តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន រដ្ឋអាជ្ញា តទល់នឹង នរម៉ាន, ហ្វូហ្វាណា និងខុនដឹវ៉ា, SCSL-04-14-A, ២០០៨, ទំព័រទី១៩០, *សូមមើល* Julie McBride, *The War Crime of Child Soldier Recruitment*, ឆ្នាំ ២០១៤, ទំព័រទី ១៣៧។

[១៤៤] *សូមមើល* Juline McBride, *The War Crime of Child Soldier Recruitment*, ទំព័រទី ១៣៨។

[១៤៥] ដូចលេខយោងខាងលើ, ទំព័រទី ១៤២។

ប្រព្រឹត្តបទល្មើសណាមួយ ដោយមិនមានចេតនា ហើយប្រើប្រាស់ធាតុអន្តោម័តដែល ទាល់តែជនល្មើសបានដឹងថាសកម្មភាពខ្លួនជាការហាមឃាត់វិញ ជាហេតុធ្វើឱ្យ អង្គជំនុំជំរះលើកចោលការចោទប្រកាន់លោក Allieu Kondewa (អាលីវ កូនឌីវ៉ា)។[១៤៦]

ការកំណត់អតិបរមាអាយុរបស់កុមារក្នុងបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម ការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងជម្លោះប្រដាប់អាវុធ ក៏ត្រូវបានចាត់ទុកថាជាបញ្ហាប្រឈមមួយផងដែរ។[១៤៧] បើទោះបីជា ការិយាល័យរដ្ឋអាជ្ញា ទទួលស្គាល់ថា "កុមារ" សំដៅលើបុគ្គលណាដែលមានអាយុក្រោម ១៨ឆ្នាំស្របតាម សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស និងមាត្រា២៦ នៃលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ១៩៩៨ ដែលចែងថា "តុលាការព្រហ្មទណ្ឌអន្តរជាតិមានលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ១៩៩៨ កំណត់បទល្មើសការកេណ្ឌ និងបញ្ចូលទាហានកុមារក្រោមអាយុ ១៥ឆ្នាំ ដែលធ្វើឱ្យកុមារចាប់ពីអាយុ១៥ឆ្នាំ ដល់ក្រោម ១៨ឆ្នាំមិនទទួលបានការការពារដូចគ្នានៅក្នុងយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ ជាហេតុធ្វើឱ្យមានបទល្មើសប្រព្រឹត្តឡើងចំពោះក្មេងៗដែលមានអាយុចាប់ពី ១៥ឆ្នាំដល់ក្រោម ១៨ឆ្នាំ។[១៤៨] បើទោះបីជា ក្នុងពិធីសារជម្រើសតាមចិត្ត ចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារបានបន្ថែមការការពារសម្រាប់កុមារក្រោម ១៨ឆ្នាំក៏ដោយ ក៏មានតែប្រទេសចំនួន ១៧៣ ក្នុងចំណោមប្រទេសចំនួន ១៩៣ នៃសមាជិកអង្គការសហប្រជាជាតិបានផ្តល់សច្ចាប័ន។[១៤៩]

លើសពីនេះបញ្ហាប្រឈមនឹងការអនុវត្តច្បាប់គឺ ដោយសារតែតុលាការអន្តរជាតិពុំមានកម្លាំងសមត្ថកិច្ចផ្ទាល់ខ្លួនឡើយ ដោយតុលាការពឹងផ្អែកទាំងស្រុងលើរដ្ឋក្នុងការឃាត់ខ្លួន និងកាត់ទោសលើជនល្មើស ធ្វើឱ្យរដ្ឋដែលមិនគោរពតាមតុលាការ នៅតែអាចប្រព្រឹត្តបទល្មើសប្រើប្រាស់ទាហានកុមារដដែល។ [១៥០]

ជារួមមក បើទោះបីជាមានច្បាប់អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើងដើម្បីដាក់ទោសជនដែលបានប្រើប្រាស់ទាហានកុមារក៏ដោយ ក៏យើងឃើញថា ច្បាប់ទាំងនេះនៅមិនទាន់គ្រប់គ្រាន់

---

[១៤៦] *សូមមើល* Juline McBride, *The War Crime of Child Soldier Recruitment*, ទំព័រទី ១៤២។

[១៤៧] ការិយាល័យរដ្ឋអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិស្តីពី គោលការណ៍លើកុមារ, រកបានលើគេហទំព័រ https://www.icc-cpi.int/sites/default/files/iccdocs/otp/20161

[១៤៨] ដូចលេខយោងខាងលើ,ទំព័រទី២។

[១៤៩] *សូមមើល* កម្រងសន្ធិសញ្ញានៃអង្គការសហប្រជាជាតិ, *រកបានលើគេហទំព័រ*, https://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-11-b&chapter=4&clang=_en

[១៥០] *សូមមើល* Sandhya Nair, *Child Soldiers And International Criminal Law: Is The Existing Legal Framework Adequate To Prohibit The Use Of Children In Conflict ?*, ឆ្នាំ ២០១៧, ទំព័រទី ៥៣។

ក្នុងការបញ្ឈប់ការប្រើប្រាស់ទាហានកុមារនៅឡើយទេ។ ពោលគឺ នៅមានចន្លោះខ្វះខាតជាច្រើន ដែលត្រូវអភិវឌ្ឍបន្ត ដើម្បីឆ្លើយតបនឹងការប្រើប្រាស់ទាហានកុមារនាពេលបច្ចុប្បន្ន។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើ ប្រធានបទខាងលើកន្លងមក អាចសង្កេតឃើញថា ក្រោយពីថ្លឹងថ្លែងផលប៉ះពាល់ និងប្រយោជន៍របស់កុមារ ដែលត្រូវបានប្រើប្រាស់ជាកងកម្លាំងប្រដាប់អាវុធសហគមន៍អន្តរជាតិបានហាមឃាត់ការប្រើប្រាស់ទាហានកុមារ ដោយបង្កើតច្បាប់ និងតុលាការអន្តរជាតិ ព្រមទាំងតុលាការAd Hoc សម្រាប់កាត់ទោសលើជនដែលបានប្រព្រឹត្តអំពើនេះយ៉ាងតឹងរឹង។

ច្បាប់អន្តរជាតិជាច្រើនបានចែងអំពីការការពារកុមារ និងយុវជនដោយបានកំណត់និយមន័យ ទាហានកុមារ គឺសំដៅលើកុមារមានអាយុក្រោម ១៨ឆ្នាំ ដែលបានចូលរួមក្នុងកងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬក្នុងជម្លោះប្រដាប់អាវុធ។ ប៉ុន្តែនាពេលបច្ចុប្បន្ន ដើម្បីអាចចាត់ទុកជា ឧក្រិដ្ឋកម្មសង្គ្រាម ដើម្បីធ្វើការដាក់ទោសតាមផ្លូវតុលាការបាន គឺទាល់តែអំពើកេណ្ឌ បញ្ចូល ឬចាប់យកកុមារដែលមានអាយុក្រោម ១៥ឆ្នាំមកចូលក្នុងកងកម្លាំងប្រដាប់អាវុធ ហើយកើតឡើងក្នុងអំឡុងពេលដែលមានជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ និងមិនមានចរិកលក្ខណៈអន្តរជាតិ។ ការកាត់ទោសតាមផ្លូវតុលាការ ពិតជាបាន ចូលរួមជាចំណែកក្នុងការបញ្ឈប់ការប្រើប្រាស់ទាហានកុមារបានមួយផ្នែកពិតប្រាកដមែន។ យ៉ាងណាមិញ យើងឃើញមានភាពខ្វះចន្លោះមួយចំនួនរបស់ច្បាប់អន្តរជាតិ ដែលជាឧបសគ្គរាំងក្នុងការលុបបំបាត់ការកេណ្ឌ និងប្រើប្រាស់ទាហានកុមារ។

ជាក់ស្តែង ការកំណត់អតិបរមានៃអាយុកុមារក្នុងធាតុផ្សំបទឧក្រិដ្ឋកម្មសង្គ្រាមគឺត្រឹមអាយុក្រោម ១៥ឆ្នាំប៉ុណ្ណោះ គឺជាអតិមរមាដែលនៅក្នុងកម្រិតទាប ធ្វើឱ្យកុមារដែលមានអាយុចន្លោះពី១៥ ដល់ក្រោម១៨ឆ្នាំក្លាយជាក្រុមងាយរងគ្រោះក្នុងជម្លោះប្រដាប់អាវុធ។

យើងសង្កេតឃើញទៀតថា បើទោះបីជាមានច្បាប់អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិហាមប្រាមក៏ដោយ ក៏មេក្រុមឧទ្ទាមនៅតាមបណ្តាប្រទេស ពិសេសនៅតំបន់អាហ្វ្រិក នៅតែចាប់យកកុមារដែលមានអាយុក្រោម ១៥ឆ្នាំ ខ្លះទើបតែមានអាយុ ៧ឆ្នាំ មកចូលក្នុងក្រុមប្រដាប់អាវុធរបស់ខ្លួន។ ក្មេងៗដែលត្រូវបានចាប់បង្ខំឱ្យចូលក្នុងកងកម្លាំងប្រដាប់អាវុធនោះត្រូវទទួលនូវការបង្ខិតបង្ខំជាច្រើនដូចជា ក្មេងប្រុសទាំងនោះត្រូវបានគេបង្ខំឱ្យប្រើប្រាស់ថ្នាំញៀន ពង្វក់ស្មារតីឱ្យហ៊ានប្រព្រឹត្តអំពើកាចសាហាវ ដូចជាសម្លាប់ជនស៊ីវិល ម៉្យាងទៀតក្មេងស្រីភាគច្រើនត្រូវបានគេបង្ខំឱ្យបម្រើផ្លូវភេទ។ តុលាការ និងច្បាប់អន្តរជាតិពិតជាជួបបញ្ហាជាខ្លាំងក្នុងការអនុវត្តច្បាប់របស់ខ្លួន ដោយហេតុថា ភាគច្រើននៃការប្រើប្រាស់ទាហានកុមារ គឺធ្វើឡើងដោយពួកក្រុមឧទ្ទាមបណ្តាលឱ្យការចាប់ខ្លួន និងឃាត់ខ្លួនត្រូវពឹងផ្អែកលើរដ្ឋនីមួយៗទាំងស្រុង និងមិនសូវមានប្រសិទ្ធិភាពឡើយ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានស្វែងយល់ និងស្រាវជ្រាវការអនុវត្តរបស់ច្បាប់អន្តរជាតិហាមប្រាមការប្រើប្រាស់ទាហានកុមារកន្លងមក យើងខ្ញុំយល់ឃើញថា ការអភិវឌ្ឍន៍នៃច្បាប់អន្តរជាតិជាច្រើន តាំងពីក្រោយសង្គ្រាមលោកលើកទី ២ រហូតដល់មានការបង្កើតតុលាការអន្តរជាតិ កាត់ទោសលើបុគ្គលដែលបានប្រើប្រាស់ទាហានកុមារ គឺពិតជាបានចូលរួមដោះស្រាយបញ្ហានេះបានមួយកម្រិត។ ក្នុងអំឡុងពេលនៃការស្រាវជ្រាវ យើងខ្ញុំក៏បានជួបនឹងបញ្ហាមួយចំនួនដូចជា ឯកសារពាក់ព័ន្ធ និងឯកសារផ្លូវការសុទ្ធសឹងតែសរសេរជាភាសាបរទេស ប៉ុន្តែយ៉ាងណាក៏ដោយ យើងខ្ញុំបានព្យាយាម និងស្វះស្វែងអស់ពីសមត្ថភាព ដើម្បីសម្រិតសម្រាំងឱ្យបាននូវការសិក្សាស្រាវជ្រាវនេះ។

ទន្ទឹមនឹងនេះ យើងខ្ញុំក៏បានយល់ដឹងបន្ថែមអំពី ការអនុវត្តនៃច្បាប់អន្តរជាតិទាំងនោះកាន់តែស៊ីជម្រៅមួយកម្រិតទៀត។ ទន្ទឹមនឹងការស្រាវជ្រាវនេះ យើងបានយល់ឃើញថាគប្បីមានការកែតម្រូវ និងបន្ថែមនូវចំណុចតូចៗមួយចំនួនក្នុងគោលបំណងឱ្យការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធិភាពឆ្លើយតបនឹងបញ្ហាប្រើប្រាស់ទាហានកុមារនាពេលបច្ចុប្បន្ន និងការពារអតីតទាហានកុមារក្នុងការចូលមករស់នៅក្នុងសង្គមឡើងវិញ។ យើងខ្ញុំសូមលើកយកអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ការពង្រីកវិសាលភាពនៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ១៩៩៨ ដោយតំឡើងអតិបរមានៃអាយុទាហានកុមារដល់ក្រោម ១៨ឆ្នាំ ក្នុងគោលដៅដាក់ទោសរាល់ជនដែលបានប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ។
- ពង្រឹងប្រព័ន្ធផ្សព្វផ្សាយច្បាប់ ដើម្បីអប់រំសហគមន៍នៅគ្រប់បណ្តាប្រទេសបានយល់ដឹងអំពីផលអវិជ្ជមាននៃការប្រើប្រាស់ទាហានកុមារ និងសារៈសំខាន់នៃការការពារសិទ្ធិកុមារ។ លើសពីនេះ បង្កើតនូវយុទ្ធនាការអប់រំកាត់បន្ថយការរើសអើងអតីតទាហានកុមារដែលនឹងត្រូវចូលមករស់នៅក្នុងសង្គមវិញ។
- ចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចនៅបណ្តាប្រទេស និងសហគមន៍ ដោយហេតុថាបញ្ហាសេដ្ឋកិច្ចជាឫសគល់នៃការប្រើប្រាស់ទាហានកុមារ បណ្តាលមកពីភាពក្រីក្រ កង្វះការអប់រំ ធ្វើឱ្យកុមារងាយរងគ្រោះក្នុងការជ្រើសរើសចូលក្នុងជម្លោះប្រដាប់អាវុធ។
- ការចូលរួមការពារជាសកល ដែលក្នុងន័យនេះតម្រូវឱ្យសហគមន៍អន្តរជាតិយកចិត្តទុកដាក់លើបញ្ហានេះក្នុងការដោះស្រាយ និងចូលរួមសហការតាមចាប់ឧក្រិដ្ឋជនដែលបានប្រព្រឹត្ត។
- ការចូលរួមផ្ទាល់ពីសហគមន៍អន្តរជាតិ និងច្បាប់ជាតិ ដើម្បីធានាការការពារដល់កុមារយ៉ាងម៉ត់ចត់ពិសេសកុមារក្នុងតំបន់ដែលមានជម្លោះប្រដាប់អាវុធ។

- ការធ្វើឱ្យប្រសើរឡើងនូវការធ្វើសមាហរណកម្មកុមារចូលក្នុងសង្គមវិញ ដែលធ្វើយ៉ាងណាឱ្យពួកគេចូលទៅក្នុងសង្គម ដោយគ្មានការរើសអើង និងផ្តល់ឱ្យអតីតទាហានកុមារជំនួយខាងស្មារតី។

ជាចុងក្រោយ យើងខ្ញុំសូមកោតសរសើរចំពោះការរួបរួមគ្នារវាងបណ្តាប្រទេសលើពិភពលោក ក៏ដូចជាអង្គការអន្តរជាតិ ដែលបានស្វែងរកនូវគ្រប់មធ្យោបាយ ដើម្បីការពារដល់កុមារ ដែលជាវ័យងាយរងគ្រោះអំពីកងកម្លាំងប្រដាប់អាវុធនិងជម្លោះប្រដាប់អាវុធដែលជាបញ្ហាធ្វើឱ្យសិទ្ធិកុមារត្រូវបានរំលោភបំពាន។ បើទោះបីជានៅមានកង្វះខាតចំណុចមួយចំនួនក្តី ក៏យើងខ្ញុំសង្ឃឹមថាសហគមន៍អន្តរជាតិនៅតែបន្តអភិវឌ្ឍ និងពង្រីកវិសាលភាពនៃច្បាប់អន្តរជាតិ ដើម្បីលុបបំបាត់ចោលឱ្យអស់នូវការប្រើប្រាស់ទាហានកុមារ ឈានទៅរកការគោរពសិទ្ធិកុមារយ៉ាងពេញលេញ។

# គន្លនិខ្មេស

# គន្ថនិទ្ទេស

## លិខិតបទដ្ឋានគតិយុត្តិ

- សេចក្តីប្រកាសសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋនៃប្រទេសបារាំង ឆ្នាំ១៧៨៩
- ធម្មនុញ្ញអង្គការសហប្រជាតិ ឆ្នាំ១៩៤៥
- វិធានធម្មនុញ្ញទីក្រុងឡុងដ៍ ឆ្នាំ១៩៤៥
- លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៤៥
- អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩
- កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦
- កតិកាសញ្ញាស្តីពីសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ ឆ្នាំ១៩៦៦
- អនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩
- ពិធីសារបន្ថែមទី១ និងទី២ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៧៧
- អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩
- លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌសម្រាប់អតីតយូហ្គោស្លាវី ឆ្នាំ១៩៩៣
- លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌសម្រាប់រវ៉ាន់ដា ឆ្នាំ១៩៩៤
- លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ១៩៩៨
- ធាតុផ្សំនៃបទល្មើសរបស់តុលាការតុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ២០០០
- លក្ខន្តិកៈស្តីពីតុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន ឆ្នាំ២០០០
- ពិធីសារជម្រើសទី១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ឆ្នាំ២០០១

## យុត្តិសាស្ត្ររបស់តុលាការ

- តុលាការព្រហ្មទណ្ឌអន្តរជាតិ, សេចក្តីសម្រេចក្នុងរឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង ថូម៉ាសលូបាងហ្គា ស្តីពីដីការបង្គាប់ឱ្យចាប់ចខ្លួន ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០០៦
- តុលាការព្រហ្មទណ្ឌអន្តរជាតិ, សេចក្តីសម្រេចក្នុងរឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង ថូម៉ាសលូបាងហ្គា ស្តីពីការសម្រេចចិត្តការចោទប្រកាន់ ថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០០៧

- តុលាការព្រហ្មទណ្ឌអន្តរជាតិ, សាលក្រមប្រកាសទោស លើរឿងក្តីរដ្ឋអាជ្ញា តទល់នឹង ថូម៉ាស លូបាងហ្គា ថ្ងៃទី ១៤ ខែមិនា ឆ្នាំ២០១២
- តុលាការព្រហ្មទណ្ឌអន្តរជាតិ, សាលក្រម ក្នុងរឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង ប៉ែមបា ស្តីពីការសម្រេចចិត្តការចោទប្រកាន់ ថ្ងៃទី ២១ ខែមិនា ឆ្នាំ២០១៦
- តុលាការសម្រាប់ប្រទេសសេរ៉ាឡេអូន, សាលក្រមក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង សេម ហ៊ីងណានរម៉េន (Sam Hinga Norman) ថ្ងៃទី៣១ ខែមេសា ឆ្នាំ២០០៤
- តុលាការព្រហ្មទណ្ឌអន្តរជាតិ, សាលក្រមលើរឿងក្តីរដ្ឋអាជ្ញា តទល់នឹង ណាហ្គានដា ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩
- តុលាការព្រហ្មទណ្ឌអន្តរជាតិ, សាលក្រមលើរឿងក្តីរដ្ឋអាជ្ញា តទល់នឹង អុងវេន (Dominic Ongwen), ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១
- តុលាការយោធាអន្តរជាតិ Nuremburg, សេចក្តីសម្រេចចុះថ្ងៃទី ១ ខែតុលា ឆ្នាំ១៩៤៦

## សៀវភៅបោះពុម្ព


- Francis, David J. "'Paper Protection' Mechanisms: Child Soldiers and the International Protection of Children in Africa's Conflict Zones." The Journal of Modern African Studies 45, no. 2 (2007): 207–31. https://doi.org/10.1017/S0022278X07002510
- Lasley, Trace, and Clayton Thyne. "Secession, Legitimacy and the Use of Child Soldiers." Conflict Management and Peace Science 32, no. 3 (2015): 289–308. https://www.jstor.org/stable/26271390.
- David P. Steward, "International Criminal Law in a Nutshell", 2nd ed., 2014.
- ROSEN, DAVID M. Child Soldiers in the Western Imagination: From Patriots to Victims. Rutgers University Press, 2015. http://www.jstor.org/stable/j.ctt17rw503.
- H.W, Koch, "H.W. Koch, The Hitler Youth: Origins and Development 1922-1945", 2000.

## ឯកសារផ្សេងទៀត

- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ

## គេហទំព័រអនឡាញ

- https://digitallibrary.un.org/?ln=en
- https://ihl-databases.icrc.org/en
- https://www.amnesty.org/en/
- https://www.hrw.org/
- https://www.icc-cpi.int/decisions
- https://www.jstor.org/
- https://www.legal-tools.org
- https://www.refworld.org

# ឧបសម្ព័ន្ធ

# ធម្មនុញ្ញសហប្រជាជាត

# Charter of the United Nations


បណ្ណាល័យច្បាប់-Law Library

lawlibrarysite.wordpress.com

# ធម្មនុញ្ញសហប្រជាជាតិ

យើងជាប្រជារាស្ត្រ នៃសហប្រជាជាតិ ដែលបានសម្រេចគ្នាថានឹងការបារធច្ឆាជនៈកូនចៅទៅអានាគតមិនឲ្យមានសង្គ្រាម ព្រោះមហាសង្គ្រាមដែលកើតមានរយៈពេលពីរលើកមកហើយបានធ្វើអោយមានសេចក្តីទុក្ខពន់ប្រមាណដល់មនុស្សជាតិ។

ក្រកាសជាថ្មី នូវជំនឿរបស់យើងក្នុងសិទ្ធិជាសារៈនៃមនុស្សក្នុងសេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្សជាតិក្នុងសមភាពនៃសិទ្ធិបុរស និងស្ត្រីព្រមទាំងប្រជាជាតិទាំងធំទាំងតូច។

បង្កើតលក្ខខណ្ឌ ជាការចាំបាត់ក្នុងការរក្សាទុក នូវយុត្តិធម៌ និងសេចក្តីគោរព កាតព្វកិច្ច នៃសន្ធិសញ្ញា និងប្រភេពដទៃ នៃសន្ធិសញ្ញាអន្តរជាតិ។

ជួយឲ្យមានវឌ្ឍនភាពខាងសង្គម និងបង្កើតលក្ខខណ្ឌជីវភាពដ៏ប្រពៃក្នុងសេរីភាពដ៏ធំទូលាយ។

# ហើយអំពីគោលបំណងនេះ

នឹងប្រតិបត្តិការអត់ឱន ការរស់នៅក្នុងសង្គមសន្តិភាពជាមួយគ្នាដោយគំនិតជាអ្នកជិតខាងល្អរួមកម្លាំងគ្នាដើម្បីរក្សាទុកនូវសន្តិភាព និងសន្តិសុខអន្តរជាតិ។

ទទួលប្រតិបត្តិគោលការណ៍ច្បាប់ និងបង្កើតរបៀបយ៉ាងធំ ដែលមិនត្រូវអោយប្រើកម្លាំងអាវុធរៀរលែងតែចំពោះប្រយោជន៍រួមគ្នា។

ពឹងផ្អែកទៅលើស្ថាប័នអន្តរជាតិ ដើម្បីជួយអោយមានវឌ្ឍនភាពខាងសេដ្ឋកិច្ច និងសង្គមដល់ប្រជារាស្ត្រទាំងអស់។

# បានសម្រេចចិត្តស្ម័គ្រស្មាគមកម្លាំងគ្នាដើម្បីបំណង ខាងលើនេះអោយសម្រេចពិតប្រាកដ

ហេតុដូច្នេះ រដ្ឋាភិបាលយើងរៀងខ្លួន តាមរយៈនៃតំណាងដែលរួមប្រជុំទីក្រុង «សង់ហ្វ្រង់ស៊ីស្កូ» ហើយដែលមានអំណាចយ៉ាងពេញលេញ បានអនុម័តបច្ចុប្បន្នធម្មនុញ្ញនៃសហប្រជាជាតិហើយដោយអាស្រ័យសហប្រជាជាតិនេះ ទើបស្ថាបនានូវអង្គការអន្តរជាតិមាននាមជា «សហប្រជាជាតិ»។

# ជំពូកទី១

## វត្ថុបំណង និង គោលច្បាប់

**ប្រការ ១៖** វត្ថុបំណងនៃសហប្រជាជាតិមានដូចតទៅនេះ៖

១-រក្សាទុកនូវសន្តិភាព និងសន្តិសុខអន្តរជាតិ ហើយដើម្បីសម្រេចនូវបំណងនេះ គឺត្រូវប្រព្រឹត្តិវិធានការរួបរួមគ្នាដ៏សក្តិសិទ្ធិដើម្បីការពារ និងបញ្ចៀសមិនឲ្យមានការកំហែងមកលើសន្តិភាព និងបង្ក្រាបអំពើរាតត្បាតទាំងអស់ ឬអំពើអ្វីដទៃដែលធ្វើឲ្យប្រេះឆាសន្តិភាព ហើយធ្វើឲ្យសម្រេចពិតប្រាកដនូវបទបញ្ហានៃការខ្វែងយោបល់គ្នា ឬបទបញ្ហានៃស្ថានការណ៍ទាំងឡាយមានលក្ខណៈជាអន្តរជាតិដែលអាចនាំឲ្យសន្តិភាពប្រេះឆាតាមមធ្យោបាយខាងសន្តិវិធី អនុឡោមតាមគោលច្បាប់យុត្តិធម៌ និងសិទ្ធិអន្តរជាតិ។

២-ពង្រីកវវាងប្រជាជាតិនូវការប្រាស្រ័យទាក់ទងជាមិត្តភាព ដែលកើតឡើងតាមសេចក្តីគោរពគោលច្បាប់ សមភាព នៃសិទ្ធិប្រជារាស្ត្រ ហើយហានឹងមានសិទ្ធិចាត់ចែងដោយខ្លួនឯង ព្រមទាំងចាត់វិធានការដទៃទាំងអស់ដ៏សមរម្យ ដើម្បីពង្រឹងសន្តិភាពក្នុងលោក។

៣-បង្កើតឲ្យមានពិតប្រាកដ នូវសហប្រតិបត្តិការ អន្តរជាតិដោយដោះស្រាយ នូវបញ្ហាអន្តរជាតិខាងសេដ្ឋកិច្ច សង្គមកិច្ច ឬមនុស្សធម៌ ដោយពង្រីក និងលើកទឹកចិត្តក្នុងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសាធារណៈសម្រាប់មនុស្សទូទៅឥតសម្គាល់ ជាតិសាសន៍ ភេទ ភាសា ឬ សាសនា។

៤-ជាទីប្រជុំមួយ ដើម្បីរួបរួមកម្លាំងនៃប្រជាជាតិ ឆ្ពោះទៅរកគោលបំណងរួមគ្នា។

**ប្រការ ២៖** អង្គការសហប្រជាជាតិ និងសមាជិក ក្នុងការស្វែងរកគោលបំណងដែលបានចែងទុកត្រង់ប្រការ១ ត្រូវប្រព្រឹត្តអនុឡោមតាមគោលច្បាប់ដូចតទៅ៖

១-អង្គការនេះបង្កើតឡើងតាមគោលសមភាពប្រកបដោយអធិបតេយ្យ នៃសមាជិកទាំងអស់។

២-សមាជិកនៃអង្គការ ត្រូវបំពេញដោយសុចរិត នូវកាតព្វកិច្ចដែលខ្លួនកាន់កាប់តាមគោលនៃធម្មនុញ្ញបច្ចុប្បន្នដើម្បីធានារ៉ាប់រងដល់ការប្រតិបត្តិសិទ្ធិ និងអត្ថប្រយោជន៍គ្រប់យ៉ាងដែលបណ្តាយមកពីគុណសម្បត្តិនៃសមាជិក។

៣-សមាជិក នៃអង្គការត្រូវសម្រួលការខ្វែងយោបល់អន្តរជាតិ តាមមធ្យោបាយសន្តិវិធីដោយសន្តិភាព និងសន្តិសុខអន្តរជាតិ ព្រមទាំងយុត្តិធម៌ មិនឲ្យធ្លាក់ចុះក្នុងសេចក្តីអន្តរាយ។

៤-ក្នុងកិច្ចប្រាស្រ័យទាក់ទងអន្តរជាតិ សមាជិក នៃអង្គការត្រូវចៀសវាង កុំពឹងផ្អែកទៅលើការកំហែង ឬការប្រើកម្លាំងប្រឆាំនឹងសម្បូរណភាព ខាងផែនដី ឬឯករាជ្យនយោបាយនៃរដ្ឋទាំងមូលក្តី ប្រឆាំងដោយរបៀបណាមួយមិនសមនឹងវត្ថុបំណង នៃសហប្រជាតិ។

៥-សមាជិកនៃអង្គការត្រូវជួយឧត្ថម្ភដោយពេញបន្ទុកអង្គការនេះ តាមអំពើដែលអង្គការនេះបានបង្កើតឲ្យមានឡើងអនុឡោមទៅតាមបទបញ្ញត្តិ នៃធម្មនុញ្ញបច្ចុប្បន្ន ហើយចៀសវាងកុំឧត្ថម្ភរដ្ឋណាមួយជារដ្ឋដែលអង្គការបានប្រព្រឹត្តនូវអំពើខាងការពារ ឬ រឹតត្បិតឆ្ពោះទៅរកនោះ។

៦-អង្គការត្រូវតែធ្វើយ៉ាងណាឲ្យរដ្ឋទាំងឡាយដែលមិនមែនជាសមាជិកនៃសហប្រជាជាតិ ប្រព្រឹត្តិអនុឡោមតាមគោលច្បាប់ខាងលើនេះ ក្នុងវិធានការជាការចាំបាច់ ដើម្បីរក្សាទ្រទ្រង់នូវសន្តិភាព និងសន្តិសុខអន្តរជាតិ។

៧-មិនមានបទបញ្ញត្តិណាមួយនៃធម្មនុញ្ញបច្ចុប្បន្ន អនុញ្ញាតឲ្យសហប្រជាជាតិធ្វើកិច្ចអន្តរាគមន៍ក្នុងរឿងទាំងឡាយដែលទាក់ទងជាដាច់ខាតទៅក្នុងសមត្ថភាពនៃរដ្ឋណាមួយ ព្រមទាំងមិនត្រូវបង្ខំសមាជិកទាំងឡាយឲ្យដាក់សម្រេចរឿងប្រភេទនេះទៅក្នុងបទវិនិច្ឆ័យនៃបទបញ្ញត្តិ តាមគោលធម្មនុញ្ញបច្ចុប្បន្ន ក៏ប៉ុន្តែគោលបែបនេះមិនប៉ះពាល់អ្វីដល់កិច្ចអនុវត្តន៍ វិធានការនៃអំណាចរឹតត្បិតដែលមានកំណត់ទុកត្រង់ជំពូក។

## ជំពូកទី២

## អំពីសមាជិក

**ប្រការ ៣៖**

ដែលចាត់ទុកជាសមាជិកដើមកំណើត នៃសហប្រជាជាតិ គឺរដ្ឋទាំងឡាយណាដែលបានចូលរួមក្នុងសន្និសិទ្ធិសហប្រជាជាតិ សម្រាប់អង្គការអន្តរជាតិ ដែលតាំងនៅសង់ហ្វ្រង់ស្កូរ ក៏បានចុះហត្ថលេខាពីមុនមកលើសេចក្តីប្រកាស នៃសហប្រជាជាតិ ចុះថ្ងៃទី ១ មករា ឆ្នាំ ១៩៤២ ។ រដ្ឋទាំងឡាយនេះមិនប៉ះពាល់លើធម្មនុញ្ញបច្ចុប្បន្ន ហើយធ្វើសច្ចាប័នអនុឡោមតាមាប្រការ ១១០។

# លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ

# STATUTE OF THE INTERNATIONAL COURT OF JUSTICE

*Article 1*

THE INTERNATIONAL COURT OF JUSTICE established by the Charter of the United Nations as the principal judicial organ of the United Nations shall be constituted and shall function in accordance with the provisions of the present Statute.

## CHAPTER I

### ORGANIZATION OF THE COURT

*Article 2*

The Court shall be composed of a body of independent judges, elected regardless of their nationality from among persons of high moral character, who possess the qualifications required in their respective countries for appointment to the highest judicial offices, or are jurisconsults of recognized competence in international law.

*Article 3*

1. The Court shall consist of fifteen members, no two of whom may be nationals of the same state.

2. A person who for the purposes of membership in the Court could be regarded as a national of more than one state shall be deemed to be a national of the one in which he ordinarily exercises civil and political rights.

*Article 4*

1. The members of the Court shall be elected by the General Assembly and by the Security Council from a list of persons nominated by the national groups in the Permanent Court of Arbitration, in accordance with the following provisions.

